**BMI0121**

## សម្ភាសន៍ជាមួយឈ្មោះ ពាក់ ធឿយ ភេទប្រុស អាយុ៥៧ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានកងធារាសាស្ត្រប្រចាំឃុំបន្ទាយឆ្មារ
## មុខងារបច្ចុប្បន្នៈ មេភូមិបន្ទាយឆ្មារខាងជើង
## សព្វថ្ងៃរស់នៅភូមិបន្ទាយឆ្មារខាងជើង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ហ៊ិន សុធានី
## ០១:២២:៤០
## ៥៣ទំព័រ

ធានី : ថ្ងៃហ្នឹងថ្ងៃទី១១ ខែ១២ ឆ្នាំ២០១០ ។ ខ្ញុំឈ្មោះធានី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះសុំអនុញ្ញាតិសម្ភាសន៍ពូ ទាក់ទងពីប្រវត្តិរបស់ពូកាលពីមុនរហូតមកដល់ឥឡូវចឹង ហើយប្រវត្តិទាំងអស់នេះ ខ្ញុំសុំយកទៅសរសេរជាសៀវភៅ ក៏ដូចជាសម្រាប់សិក្សា ឬក្មេងៗក្រោយបានស្រាវជ្រាវ រៀនសូត្រដឹងរឿងអស់ហ្នឹង ពូណា៎ ។

ធឿយ : បាទ!

ធានី : សុំសួរពូឈ្មោះអីដែរ?

ធឿយ : ខ្ញុំឈ្មោះ ពាក់ ធឿយ ។

ធានី : ពាក់ ធឿយ?

ធឿយ : បាទ!

ធានី : ឆ្នាំហ្នឹងពូអាយុប៉ុន្មានហើយ?

ធឿយ : កាលសម័យពតឆ្នាំខ្ញុំអាយុ ។

ធានី : ពូឥឡូវ?

ធឿយ : អឺ! ៥៧ឆ្នាំ ។

ធានី : ពូមានស្រុកកំណើតនៅណា?

ធឿយ : នៅបន្ទាយឆ្មារ ។

ធានី : ស្រុកកំណើតនៅភូមិឃុំអី?

ធឿយ : បន្ទាយឆ្មារខាងជើង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ។

ធានី : ភូមិបន្ទាយឆ្មាខាងជើង ឃុំអីគេ?


66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ធឿយ ៖ ឃុំបន្ទាយឆ្មារ ។

ធានី ៖ ស្រុកថ្មពួក ខេត្ត?

ធឿយ ៖ បាទ! កំណើតខេត្តបាត់ដំបង ។

ធានី ៖ ចឹងនៅភូមិឃុំហ្នឹងដដែល ប៉ុន្តែនៅខេត្តបាត់ដំបង?

ធឿយ ៖ បាទ!

ធានី ៖ ទើបតែឥឡូវបានគេដូរដាក់ខេត្តបន្ទាយមានជ័យ?

ធឿយ ៖ បាទ! នោះដាក់៨៧ក្រោយ ។

ធានី ៖ ចឹងឆ្នាំ១៩៨៧ បានប្តូរពី ៨៧ ឬ៨៨ ពូ?

ធឿយ ៖ ៨៧ ៨៨ហ្នឹង ព្រោះក្នុងរៀនគេដាក់៨៧ក៏បាន ៨៨ក៏បាន មកបន្ទាយមានជ័យវិញ ។

ធានី ៖ ចឹងឪពុកពូឈ្មោះអីគេ?

ធឿយ ៖ ឪពុកខ្ញុំឈ្មោះ វ៉ាន់ ពាក់ ។

ធានី ៖ គាត់នៅរស់ទេ?

ធឿយ ៖ ស្លាប់ ។

ធានី ៖ ពេលណាដែលពូ?

ធឿយ ៖ ប៉ុលពតសម្លាប់ ។

ធានី ៖ ហេតុអី ដោយសារអីដែរ?

ធឿយ ៖ គាត់ អឺ!គាត់កាន់ទាហានស្វាយត្រាណផង ហើយគាត់ជាជំទុកលេខ១ផង ។

ធានី ៖ ទាហានលន់ នល់?

ធឿយ ៖ ទាហាន បាទ!ទាហានលន់ នល់ គេហៅទាហានស្វាយត្រាណ ។

ធានី ៖ ស្វាយត្រាណហ្នឹងទាហានអីគេ?

ធឿយ ៖ ទាហានប្រចាំឃុំ ។

ធានី ៖ ទាហានប្រចាំឃុំ ហើយគាត់ធ្វើជាមេឃុំទៀត?

ធឿយ ៖ បាទ! ជំទុកលេខ១ ។

ធានី ៖ ជំទុកទី១ឃុំអីគេ?

ធឿយ ៖ ឃុំបន្ទាយឆ្មារ ។

ធានី ៖ ចុះម្តាយពូ?

ធឿយ ៖ ម្តាយឈ្មោះ ណៅ ហ៊ុន ។

ធានី ៖ គាត់នៅរស់ ហើយស្លាប់?

ធឿយ ៖ ស្លាប់ ។

ធានី ៖ ស្លាប់ដោយសារអីគេ?

ធឿយ ៖ ដោយសារជម្ងឺ ។

ធានី ៖ ឈឺ?

ធឿយ ៖ បាទ!

ធានី ៖ ឆ្នាំណាទៅ?

ធឿយ ៖ គាត់ស្លាប់នៅឆ្នាំ២០០៨ដែរ ។

ធានី ៖ បងប្អូនប៉ុន្មាននាក់ដែរពូ?

ធឿយ ៖ បងប្អូនខ្ញុំ១១នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ធឿយ ៖ ស្រី៥ ។

ធានី ៖ ស្រី៥ ប្រុស៦?

ធឿយ ៖ ៦ ។

ធានី ៖ នៅរស់ទាំងអស់គ្នាទេ?

ធឿយ ៖ នៅរស់ទាំងអស់ ។

ធានី ៖ ពូជាកូនទីប៉ុន្មាន?

ធឿយ ៖ កូនទី១ ។

ធានី ៖ ចឹងពូរៀបគ្រួសារនៅឆ្នាំប៉ុន្មាន?

ធឿយ ៖ នៅឆ្នាំ១៩៧៥ ។

ធានី ៖ ៧៥ សម័យខ្មែរក្រហម?

ធឿយ ៖ បាទ! សម័យខ្មែរក្រហម ។

ធានី ៖ មុនខ្មែរក្រហម?

ធឿយ ៖ សម័យខ្មែរក្រហមគេចាប់ឲ្យរៀប ។

ធានី ៖ គ្រួសារពូឈ្មោះអី?

ធឿយ ៖ ប៉ែ សួន ។

ធានី ៖ មានកូនប៉ុន្មាននាក់ដែរពូ?

ធឿយ ៖ កូន៣នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ធឿយ ៖ ស្រី២ ប្រុស១ ។

ធានី ៖ ពូបានរៀនសូត្រអីទេ?

ធឿយ ៖ ខ្ញុំរៀនថ្នាក់ទី៧សម័យពីដើមមិញ ។

ធានី ៖ នៅសាលាណាវិញ?

ធឿយ ៖ សាលាបន្ទាយឆ្មារ ។

ធានី ៖ ចឹងពូចាប់ផ្ដើមចូលរៀនតាំងពីឆ្នាំប៉ុន្មានដែរ?

ធឿយ ៖ បាទ!

ធានី ៖ ដូចថាចាប់ផ្ដើមចូលរៀនពីឆ្នាំណាទៅ?

ធឿយ ៖ ចូលរៀន មើលខ្ញុំឈប់រៀននៅឆ្នាំ៧០គត់ ។

ធានី ៖ ឈប់រៀននៅឆ្នាំ៧០គត់?

ធឿយ ៖ បាទ! ដកមកក្រោយឃើញហើយ ។

ធានី ៖ ៧០គត់ ម៉េចបានពូឈប់រៀន?

ធឿយ ៖ វាកាលនោះ បើយើងឈប់ដោយសារសម័យលន់ នល់ វាកើតសង្គ្រាមផងអីផង វាយើងពិបាករៀន ហើយយើងត្រូវទៅរៀនឆ្ងាយ ព្រោះសាលាបន្ទាយឆ្មារនេះ វាចប់ត្រឹមថ្នាក់ទី៧ ថ្នាក់បឋម អត់មាន ។

ធានី ៖ មានសង្គ្រាម ហើយត្រូវទៅរៀនឆ្ងាយ ទើបបានអត់អាចទៅបាន?

ធឿយ ៖ បាទ! វាជួបការលំបាក ។

ធានី ៖ ហើយម៉េចទៀតពូ បន្ទាប់ពីរៀនហើយ ឈប់រៀនធ្វើអីទៅ?

ធឿយ ៖ ដល់ពេលយើងឈប់រៀនហើយ យើងធ្វើស្រែបានតែពី៧០គត់មក៧៥ វាចូលសម័យខ្មែរក្រហមមក ។

ធានី ៖ ចឹងពូអាចជួយរៀបរាប់បានទេ ថាក្រៅពីការធ្វើស្រែរហូតដល់ពេល៧៥ ដែលខ្មែរក្រហមចូលមកដល់ភូមិយើង ទិដ្ឋភាពយ៉ាងម៉េចដែរ ពេលចូលមកដំបូងម៉េច? គេនិយាយយ៉ាងម៉េចខ្លះ? ហើយម៉េចបានយើងដឹងថាអ្នកអស់ហ្នឹងជាខ្មែរក្រហម?

ធឿយ ៖ ដែលខ្មែរក្រហមវាចូលមក ។

ធានី ៖ ចាំ!

ធឿយ ៖ ចាំមើលយើងដែលខ្មែរក្រហមវាចូលមក មុនដំបូងឲ្យប្រជាពលរដ្ឋយើងវាចងក្រងជាក្រុម ។

ធានី ៖ ម៉េចទៀតពូ?

ធឿយ ៖ ចងក្រងជាក្រុម ហើយឲ្យយើងហូបបាយរួម ។

ធានី ៖ ហូបបាយរួមម៉េច? អត់ទេចូលមកដំបូងដូចថាគេនិយាយប្រាប់យ៉ាងម៉េចខ្លះ បានឲ្យយើងចងក្រងជាក្រុម?

ធឿយ ៖ បាទ! ហើយគេចូលមកគេណែនាំយើងអំពីបដិវត្ត បាទ!គេធ្វើបដិវត្តគេធ្វើខុសពីសម័យមុន គេធ្វើពីៗ បាតដៃគេថាពីបាតដៃទទេរណា ។

ធានី ៖ ម៉េចទៀតពូ?

ធឿយ ៖ ដល់ពេលគេប្រជុំគេណែនាំយើង ពីគោលការណ៍របស់គេ គេថាឲ្យយើងធ្វើស្រែ បើយើងធ្វើស្រែបាន ហើយយើងយកទៅដូរអាត្រាក់ទៅដូរអី ហើយគេនឹងតខ្សែភ្លើងឲ្យតាមស្រុកភូមិ នេះជាការណែនាំរបស់គេ ។

ធានី ៖ ចឹងប្រាប់ឲ្យប្រជាជនទាំងអស់គ្នានាំគ្នាធ្វើស្រែ?

ធឿយ ៖ បាទ! ឲ្យធ្វើស្រែ ។

ធានី ៖ អត់មាននិយាយអីទៀតណា?

ធឿយ ៖ ឲ្យធ្វើស្រែ ឲ្យយើងដាំដំណាំដាំអី ។

ធានី ៖ តែពេលហ្នឹងចងក្រងជាក្រុមហើយៗ?

ធឿយ ៖ បាទ! ចងក្រងជាក្រុម ។

ធានី ៖ ចុះទ្រព្យសម្បត្តិ ផ្ទះសម្បែងអី?

ធឿយ ៖ ទ្រព្យសម្បត្តិអី គោក្របីអីគេដាក់រួមទាំងអស់ ហើយដូចជាមាស ខ្សែកអីមានមាស យើងនិយាយពីមាសអី មេភូមិសម័យនោះ គេអាចៅសង្កាត់គេសម័យនោះ គេប្រមូលអស់ ។

ធានី ៖ ចឹងក្រែងឪពុកពូជាជំទុកដែរ ម៉េចក៏អត់មានសិទ្ធិធ្វើចឹង?

ធឿយ ៖ ព្រោះគេ យើងជាអតីត ។

ធានី ៖ ចឹងមានអ្នកមេភូមិថ្មី?

ធឿយ ៖ បាទ! ថ្មីគេមករើសថ្មី ។

ធានី ៖ ពេលគេមកតែងតាំងហ្នឹងពេលណា គេមកប្រាប់ថាគេធ្វើមេភូមិម៉ង ឬម៉េច?

ធឿយ ៖ បាទ! គេមកតែងតាំង ពេលគេចូលមកដល់ គេហៅប្រជាពលរដ្ឋមកប្រជុំ គេមកបង្ហាញមុខថាគេនេះគេមេឃុំ គេនេះគេមកប្រាប់ស្រេច ។

ធានី ៖ អ្នកណាគេ ពូមានចាំទេ?

ធឿយ ៖ ឈ្មោះតានេះ ឈ្មោះតាសាំ ។

ធានី ៖ តាសាំ?

ធឿយ ៖ ឈ្មោះសាំ ។

ធានី ៖ តាសាំ មិនមែននៅថ្មពួកទេ នៅបន្ទាយឆ្មារដែរ?

ធឿយ ៖ ថ្មពួកក៏ធ្លាប់នៅ នេះធ្លាប់នៅ ។

ធានី ៖ ចឹងតាសាំមកនៅនេះផង នៅនោះផង ឬក៏យ៉ាងម៉េច?

ធឿយ ៖ បាទ! គេផ្លាស់ចេញផ្លាស់ចូល ។

ធានី ៖ តែមកដំបូងបំផុត គឺដឹងថាតាសាំ?

ធឿយ ៖ អឺ! នេះភ្លេចឈ្មោះបាត់ហើយ ភ្លេចឈ្មោះបាត់ហើយដែលនៅមុនដំបូង វាយូរពេកហើយ ។ វាមានពួកតាតឹក តាយី មុនដំបូង ។

ធានី ៖ មុនដំបូងតាតុ?

ធឿយ ៖ តាតឹក ឈ្មោះតាតឹក តាញ៉ែបៗប្រធានសង្កាត់ ។

ធានី ៖ តាញ៉ែបប្រធានសង្កាត់ដំបូងគេ?

ធឿយ ៖ បាទ! ប្រធានដំបូងគេ ។

ធានី ៖ ប្រធានសង្កាត់បន្ទាយឆ្មារហ្នឹង?

ធឿយ ៖ បាទ! ហើយរងមកតាយី ឈ្មោះយី ឈ្មោះតឹក ។

ធានី ៖ យី តឹក?

ធឿយ ៖ បាទ! អានេះកូនចៅរបស់គេ ។

ធានី ៖ យី រង?

ធឿយ ៖ បាទ!

ធានី ៖ ហើយនេះសមាជិក(តឹក)ចឹង ពូនោះ?

ធឿយ ៖ បាទៗ ។

ធានី ៖ ហើយដល់ពេលពួកគាត់ទាំង៣នាក់ហ្នឹង គឺអ្នកណែនាំប្រជាជនឲ្យធ្វើការងារ ឲ្យប្រមូលទ្រព្យសម្បត្តិចូលឃ្លាំង ហើយជាអ្នកប្រមូលមាសប្រមូលអីដាក់ក្នុងរដ្ឋ?

ធឿយ ៖ បាទ! ហើយគាត់រើសមេភូមិឲ្យទៅ ឲ្យយើងប្រមូលជាមាសប្រាក់ដាក់ម៉ាកន្លែងរបស់គេ ។

ធានី ៖ ហេតុអីបានគេ ឲ្យប្រមូលមាស ប្រាក់ ហើយទ្រព្យសម្បត្តិផ្សេងៗដាក់ម៉ាកន្លែង?

ធឿយ ៖ យើងអត់ដឹងពីគោលការណ៍របស់គេៗថាគេឈប់ចាយ ។

ធានី ៖ គេនិយាយចឹង?

ធឿយ ៖ បាទ! គេថាគេឈប់ចាយអស់ហើយ យើងកុំទុក ហើយគេត្រូវឲ្យប្រមូល ដល់ប្រជាពលរដ្ឋ យើងខ្លាចផងទៅ យើងចេះប្រមូលឲ្យគេ ។

ធានី ៖ ខ្លាចយ៉ាងម៉េច កាលហ្នឹងមានការគំរាមកំហែង អ្នកអត់ព្រមយកទៅយ៉ាងម៉េចបាន?

ធឿយ ៖ មាន គេត្រូវសម្លាប់ ។

ធានី ៖ នៅហ្នឹងមុខយើងម៉ង?

ធឿយ ៖ បាទ! ហើយបើយើងដូចជាយើងជាប់និន្នាការអតីតទាហាន ដូចខ្ញុំនិយាយមិញ ពីឪពុកខ្ញុំអីចឹង ណា៎ ជាប់ចុះគេដឹងគេយកទៅសម្លាប់ចោល ។

ធានី ៖ ចឹងឪពុកពូសម្លាប់ពេលភ្លាមៗហ្នឹងដែរ ឬក៏អត់?

ធឿយ ៖ អឺ! គាត់នៅបាន គេសម្លាប់នៅឆ្នាំ១៩៧៧ គេទុកយើងប្រើសិន ។

ធានី ៖ ចឹងហើយ ពូពេលដែលគេនិយាយប្រកាសចឹង ហើយអ្នកផ្សេងៗអ្នកណាគេយកទៅសម្លាប់ ហើយអត់ព្រមប្រគល់ទ្រព្យសម្បត្តិដូចថាមាស?

ធឿយ ៖ អានេះវាមានពួកក្រុមគេហ្នឹងឯង គេមានឈ្លបពិសេសរបស់គេអ្នកសម្លាប់ ។

ធានី ៖ មិនមែនទេ ចង់និយាយថា អ្នកមិនព្រមឲ្យ អ្នកណាគេពូចាំឈ្មោះទេ ថាអត់ព្រម?

ធឿយ ៖ អត់ទេ រឿងមាសប្រាក់នោះគេព្រមឲ្យទាំងអស់ ព្រោះគេកម្លាចបើអ្នកណាមិនឲ្យចឹងណា ។

ធានី ៖ អូ! គេកម្លាច?

ធឿយ ៖ បាទ! ប៉ុន្តែបើសិនយើងមិនឲ្យមែនគេសម្លាប់មែន ។

ធានី ៖ តែមានទេ?

ធឿយ ៖ តែបើយើងខ្លាចទៅយើងចេះតែឲ្យ ។

ធានី ៖ ឲ្យគ្រប់គ្នាទៅ?

ធឿយ ៖ បាទ!

ធានី ៖ ប៉ុន្តែពូមើលទៅដឹងថាអាចមាន គេធ្វើមែន?

ធឿយ ៖ បាទ!

ធានី ៖ ជឿថាគេធ្វើមែនបានដាក់ឲ្យ?

ធឿយ ៖ បាទ!

ធានី ៖ ហើយចឹងបន្ទាប់មកទៀតមិននៅហ្នឹង ហើយមានគេជម្លៀសទៅណាអត់?

ធឿយ ៖ សម័យនោះ គេអត់មានជម្លៀសខ្ញុំទៅណាទេ ។

ធានី ៖ នៅភូមិយើងដដែល?

ធឿយ ៖ គេគ្រាន់តែជម្លៀសពីភូមិដែលនៅជុំវិញនេះមកនៅបន្ទាយឆ្មារ ។

ធានី ៖ មកនៅបន្ទាយឆ្មារទាំងអស់?

ធឿយ ៖ បាទ! មកនៅទាំងអស់ ។

ធានី ៖ ហើយម៉េចបានគេជម្លៀសប្រជាជនដែលនៅជុំវិញហ្នឹងមកនៅបន្ទាយឆ្មារ?

ធឿយ ៖ ព្រោះថាកាលនោះគេថា គេជម្លៀសដើម្បីការពារៗដូចជាថា អានេះជាល្បិចរបស់គេទេ ព្រោះបើសិនទឹកដីឃុំបន្ទាយឆ្មារវានៅជាប់ព្រំដែនថៃ ដល់ហើយគេត្រូវជម្លៀសឲ្យនៅរួមគ្នា បើមិនចឹងយើងរត់ទៅថៃ ។

ធានី ៖ ហើយពូចាំទេ អ្នកណាអ្នកនិយាយ អ្នកអស់ហ្នឹង តានេះហ្នឹង?

ធឿយ ៖ តានេះហ្នឹង តាញឹប ។

ធានី ៖ ហើយបន្ទាប់មកទៀតម៉េចទៀតពូ ពេលដែលគេជម្លៀសប្រជាជនហើយ អ្នកភូមិយើងម៉េចដែរ?

ធឿយ ៖ បាទ! ដែលជម្លៀសហើយចេះ យើងជម្លៀសមករស់នៅចេះ ហើយពេលណាដែលនេះ គេបង្កើតជាឈ្លប ហើយគេតាមដានៗយប់ឡើងខ្ញុំចេះ ឈ្លបអីគេនៅតាមក្រោមផ្ទះ បើសិនថាពួកយើងនិយាយថាពាក្យអត់ល្អប៉ះពាល់ដល់គេ ឈ្លបគេរាយការណ៍គេចាប់យើង ។ បាទ! គេធ្វើចុះឯង កាលសម័យហ្នឹង ។

ធានី ៖ ចុះមានប្រជាជនថ្មីមកនៅហ្នឹងទេ អ្នក១៧មេសា?

ធឿយ ៖ ប្រជាជនថ្មី ១៧មេសាអត់មានទេនៅនេះ ។

ធានី ៖ អត់មានទេ?

ធឿយ ៖ មានទៅខាងទឹកដីខាងស្រុកថ្មពួក ខាងកាប់ចាប់ចងមានអីខាងនោះមាន ។

ធានី ៖ ចុះខាងនេះអត់មានទេ?

ធឿយ ៖ អត់មានទេ អត់មានមកដល់ទេ ។

ធានី ៖ ចុះអ្នកដែលធ្វើការដូចពូ គេមាននៅប្រមូលជុំគ្នាម្ដុំទេ ឬក៏អត់ទេ នៅផ្ទះធម្មតារៀងខ្លួន?

ធឿយ ៖ នៅ គេប្រមូលមុនដំបូងយើងនៅផ្ទះជុំគ្នា ដល់ក្រោយមកគេប្រមូល គេអត់ឲ្យយើងនៅផ្ទះទេ គេឲ្យយើងចេញនៅតាមព្រៃ គេបង្កើតជាការដ្ឋានមកឲ្យយើងចេញនៅតាមព្រៃ ហើយយើង

នៅជាក្រុម ធ្វើស្រែធ្វើអីឲ្យនៅជាក្រុមចេះឯង។ ផ្ទះនេះនៅចោលអត់មានអ្នកណានៅទេ បាត់ស្ងាត់ឈឹង។

ធានី ៖ ចឹងយើងទៅនៅតាមព្រៃវិញ?

ធឿយ ៖ បាទ! នៅតាមព្រៃ។

ធានី ៖ ព្រៃម្ដុំណាវិញ?

ធឿយ ៖ ព្រៃនៅខាងនេះ នៅណាតាមនេះពេញណាពេញណៃ។

ធានី ៖ ឲ្យតែមានព្រៃ?

ធឿយ ៖ បាទ! ឲ្យតែមានព្រៃ។

ធានី ៖ ហើយគេនៅក្នុងព្រៃហ្នឹងធ្វើអី?

ធឿយ ៖ ឲ្យនៅធ្វើស្រែ។

ធានី ៖ ធ្វើស្រែក្នុងព្រៃហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ អ្នកនៅក្នុងភូមិយើងហ្នឹងអត់ធ្វើទេ ធ្វើក្នុងព្រៃវិញ?

ធឿយ ៖ ភូមិ ព្រោះភូមិនេះ វាអត់ឲ្យនៅ វាអត់ឲ្យយើងនឹងនៅផ្ទះទេ ឲ្យចេញ។

ធានី ៖ ប៉ុន្តែយើងនៅឆ្ងាយ ប៉ុន្តែយើងមកធ្វើស្រែនៅក្នុងភូមិវិញ?

ធឿយ ៖ បាទ! ហើយស្រែយើងហ្នឹងនៅជិតចេះឯង បាទ!នៅជិតតែនេះអត់ឲ្យយើងធ្វើស្រែ។

ធានី ៖ ការពេលហ្នឹងពូចង់ក្រងនៅក្នុងក្រុមអីដែរ?

ធឿយ ៖ គេកាលនោះគេមានរៀបចំជាក្រុមកុមារផ្សេង ក្រុមយុវជនផ្សេង ក្រុមវ័យកណ្ដាលផ្សេង។

ធានី ៖ ចា៎! ហើយពូនៅក្នុងក្រុមអីទៅ?

ធឿយ ៖ បាទ! ហើយខ្ញុំនៅក្រុមវ័យកណ្ដាល។

ធានី ៖ វ័យកណ្ដាលហ្នឹងគេធ្វើអីខ្លះ?

ធឿយ ៖ វ័យកណ្ដាលគេឲ្យយើងខាងធ្វើស្រែ ភ្ជួររាស់ដកស្ទូង ហើយយើងលើកទំនប់អាងអី។

ធានី ៖ ពូលើកទំនប់ដែរ?

ធឿយ ៖ បាទ!

ធានី ៖ លើកទំនប់អាងអីគេ?

ធឿយ ៖ អាងយើងនេះ អាងជើងគ្រោះ។

ធានី ៖ អាងជើងគ្រោះ?

ធឿយ ៖ បាទ!

ធានី ៖ អត់មានបានទៅអានត្រពាំងថ្មទេ?

ធឿយ ៖ ត្រពាំងថ្ម ខ្ញុំអត់បានទៅទេ ព្រោះ ។

ធានី ៖ ចង់សួរពូថា ពេលពូនៅក្នុងកងហ្នឹងហៅកងវ៉ៃកណ្ដាលចឹង វាជាកងចល័ត ឬជាកងអីគេ?

ធឿយ ៖ កងអី!ចល័ត ។

ធានី ៖ គេហៅកងចល័ត?

ធឿយ ៖ បាទ!

ធានី ៖ កងចល័តស្រុក ឃុំ ភូមិ?

ធឿយ ៖ ព្រោះខ្ញុំៗនៅចេះ អាកងចល័តឃុំក៏ខ្ញុំនៅកងចល័តស្រុកក៏ខ្ញុំនៅ ។

ធានី ៖ ចឹងហៅកងចល័តអី កងចល័តតំបន់?

ធឿយ ៖ បាទ! ដែលខ្ញុំនៅក្រោយនៅកងចល័តស្រុក ។

ធានី ៖ ចឹងដំបូងពូនៅកងចល័ត?

ធឿយ ៖ ឃុំ ។

ធានី ៖ ឃុំនៅភូរវាស់ដីហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ ដល់ពេលឡើងធ្វើអាងហ្នឹងធ្វើអាងហ្នឹងបានទៅកងចល័តស្រុក?

ធឿយ ៖ បាទ! នៅកងចល័តស្រុក ។

ធានី ៖ កងចល័តតំបន់ ចល័តឃុំ ។ ហើយកាលហ្នឹងពូនៅកងចល័តឃុំ អ្នកណាប្រធានកងចល័តហ្នឹង?

ធឿយ ៖ អឺ! ឈ្មោះប៊ុ ភ្ញីន ។

ធានី ៖ ភ្ញីនៗប្រធានកងចល័តឃុំ?

ធឿយ ៖ ស្រុក ។

ធានី ៖ កងចល័តឃុំ ឬក៏ស្រុក?

ធឿយ ៖ ស្រុក ។

ធានី ៖ ចុះឃុំនោះ?

ធឿយ ៖ ឃុំព្រោះអាកងចល័តឃុំវាពួកដែលនៅនោះឈ្មោះ ឆេង ឆឿន ។

ធានី ៖ ឆេង ឆឿន?

ធឿយ ៖ បាទ! គេច្រើនមិននិយាយចឹងទេ គេហៅកម្មាភិបាល ។

ធានី ៖ ចា៎! សមមិត្ត?

ធឿយ ៖ បាទ!

ធានី ៖ ឆេង ឆឿន ជាកងចល័តឃុំ?

ធឿយ ៖ បាទ!

ធានី ៖ ហើយការងារចឹង ពូដូចថាខែប្រាំងធ្វើអី ខែវស្សាធ្វើអី?

ធឿយ ៖ ខែប្រាំងគេឲ្យយើងធ្វើស្រូវប្រាំង ។

ធានី ៖ ធ្វើស្រូវប្រាំង?

ធឿយ ៖ បាទ! ហើយធ្វើនេះធ្វើទាំងយប់ទាំងថ្ងៃ ។ មិនមែនទេ ភ្ជួរយើងពីដើមមិញសម័យហ្នឹងគេហៅ អុចចន្លោះៗភ្ជួរ ។

ធានី ៖ ហើយពូមានទឹកសម្រាប់ធ្វើស្រែប្រាំង?

ធឿយ ៖ ទឹកអាងៗជើងគ្រោះ ។

ធានី ៖ អាងជើងគ្រោះហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ អាងជើងគ្រោះហ្នឹងគឺកន្លែងហ្នឹងសម្រាប់យកទឹកហ្នឹងធ្វើស្រែប្រាំង?

ធឿយ ៖ បាទ! សម្រាប់យកទឹកធ្វើស្រែប្រាំង ។

ធានី ៖ ហើយដល់ពេលខែវស្សាធ្វើស្រូវធ្វើអី?

ធឿយ ៖ ធ្វើស្រូវវស្សាយើងធម្មតា ។

ធានី ៖ ចឹងពូស្ទូងផង ដកផង ហើយច្រូត ហើយភ្ជួរទៀត?

ធឿយ ៖ បាទ! វាចេះ គេចែកដាច់ដោយឡែក សម័យនោះគេចែកដាច់ដោយឡែកដែលថា ដូចជាពួក ខ្ញុំខាងភ្ជួរ គេទៅភ្ជួរ ។

ធានី ៖ អូ! ចឹងពូទៅភ្ជួរមែនទេ អត់មានស្ទូងដក?

ធឿយ ៖ បាទ! ពួកអ្នកស្ទូងផ្សេង គេចែកដាច់ឡែកដោយគ្នាចឹងណា ។

ធានី ៖ ចឹងពូខាងកងភ្ជួរទេ?

ធឿយ ៖ បាទ!

ធានី ៖ ប្រធានកងចល័តភ្ជួរហ្នឹងឈ្មោះអីគេ?

ធឿយ ៖ ឈ្មោះអឺ នែក! ភ្លេចឈ្មោះវា ឈ្មោះភ្លីនដូចគ្នាចេះឯង អាមួយភ្លីននេះ អាមួយភ្លីនឡើងកង
ភ្លូរនេះអតីតយោធា ។

ធានី ៖ ចុះភ្លីនមួយទៀត?

ធឿយ ៖ អឺ! នេះមិនមែនភ្លីនទេ ប៉ុលីត ។

ធានី ៖ លីត?

ធឿយ ៖ បាទ! ប្រទ្បំ ដូរឈ្មោះៗស្រដៀងគ្នា ។ អានេះយោធាសុទ្ធហើយដែលប្រធានកងខ្ញុំ
គេបញ្ជូន មកព្រំដែន គេឲ្យមកនៅកាន់ ។

ធានី ៖ យោធា?

ធឿយ ៖ បាទ!

ធានី ៖ ដល់ពេលភ្លីនហ្នឹង មិនមែនយោធាទេ?

ធឿយ ៖ ភ្លីនហ្នឹង គឺកម្មាភិបាលចល័តស្រុក ។

ធានី ៖ ប៉ុន្តែមិនមែនយោធាដូចខាងលីតហ្នឹងទេ?

ធឿយ ៖ អត់មានយោធាដូចលីតទេ បាទ!

ធានី ៖ ដល់ពេលចឹងពេលពូនៅចឹង ចុះដល់ពេលទៅកងចល័តស្រុកហើយ នៅតែធ្វើការងារចឹងទៀត
ភ្លូរហើយនឹងលើកទំនប់អីចឹងទៀត?

ធឿយ ៖ ពេលដែលខ្ញុំចូលកងចល័តស្រុក ខ្ញុំៗគេប្រើឲ្យខ្ញុំនឹងទេខាងប្រព័ន្ធធារាសាស្ត្រ ។

ធានី ៖ ខាងលើកទំនប់ហ្នឹង?

ធឿយ ៖ ប្រព័ន្ធធារាសាស្ត្រប្រព័ន្ធប្រឡាយទឹកអីហ្នឹង ។

ធានី ៖ ទាំងខែប្រាំង ខែវស្សា?

ធឿយ ៖ បាទ! ទាំងខែប្រាំងខែវស្សាយើង ។

ធានី ៖ ធារាសាស្ត្រនឹង ពូធ្វើអីខ្លះ?

ធឿយ ៖ ភ្លឺ បិទភ្លឺ បិទប្រឡាយនេះឯង ធ្វើប្រឡាយទឹកសម្រាប់យកស្រោចស្រពស្រូវ ។

ធានី ៖ ប្រព័ន្ធធារាសាស្ត្រនឹង គឺខាងបិទភ្លឺ បិទប្រឡាយ ពេលទឹកលិចទឹកបាក់អីចឹង យើងអ្នកបិទតែ
ប៉ុនហ្នឹងទេ?

ធឿយ ៖ បាទ! ពេលយើងធ្វើអាងបានហើយចេះ យើងត្រូវមានប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោច
ស្រពស្រូវណា យើងបើកបញ្ជូន ។

ធានី ៖ ចឹងពូអ្នកនៅខាងហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ គ្នាពូប៉ុន្មាននាក់?

ធឿយ ៖ គ្នាខ្ញុំ ១០នាក់ ។

ធានី ៖ ១០នាក់?

ធឿយ ៖ បាទ!

ធានី ៖ ម្នាក់ហ្នឹង អ្នកណាជាប្រធាន?

ធឿយ ៖ បើនិយាយកាលនោះគ្នា១០នាក់ ខាងប្រធានធារាសាស្ត្រនេះ ខ្ញុំប្រធានគេ ។

ធានី ៖ ពូអ្នកប្រធានគេ?

ធឿយ ៖ បាទ! ខ្ញុំអ្នកគ្រប់គ្រង ។

ធានី ៖ ពូប្រធានខាងកងធារាសាស្ត្រចឹង?

ធឿយ ៖ បាទ!

ធានី ៖ ធារាសាស្ត្រសម្រាប់ខេត្តយើង អឺ!សម្រាប់បន្ទាយឆ្មារនេះ ឬក៏យ៉ាងម៉េច?

ធឿយ ៖ បន្ទាយឆ្មារយើង ។

ធានី ៖ ធារាសាស្ត្របន្ទាយឆ្មារ?

ធឿយ ៖ បាទ!

ធានី ៖ សម្រាប់ស្រុកបន្ទាយឆ្មារ ឬក៏សម្រាប់ឃុំទេ?

ធឿយ ៖ ឃុំៗបន្ទាយឆ្មារ ។

ធានី ៖ តែក្នុងឃុំមួយទេ ពូនោះ មិនដល់ទៅដល់ស្រុកទេ?

ធឿយ ៖ បាទ! ឃុំ ប៉ុន្តែវាខ្ញុំ ដំណាក់កាលចឹង ។ ពេលដែលខ្ញុំចេញពីនេះគេបញ្ជូនខ្ញុំទៅត្រពាំងថ្មទៀត ប៉ុន្តែខ្ញុំមិនបានលើកទំនប់ទេ គេបញ្ជូនមកខាងធារាសាស្ត្រ ។

ធានី ៖ ទៅខាងធារាសាស្ត្រនឹងដែរ?

ធឿយ ៖ បាទ! ទៅដល់នោះគេបញ្ជូនទៅខាងធារាសាស្ត្រតំបន់ ។

ធានី ៖ ចឹងពូអ្នកបើកទឹកបញ្ជូនក្នុងប្រឡាយ?

ធឿយ ៖ អត់មានបានបើកទេ តួនាទីខ្ញុំគ្រាន់តែគំរង់វាស់វែងឲ្យគេ រឿងបើកបច្ចេកទេសនៅលើគេផ្សេង ។

ធានី ៖ ចឹងក្រែងពូខាងធារាសាស្ត្រហ្នឹងអត់ខាងបើកទឹកទេ គឺខាង?

ធឿយ ៖ អត់ទេ គឺខាងយើងប្រព័ន្ធ ។

ធានី ៈ ប្រព័ន្ធ?

ធឿយ ៈ បាទ!

ធានី ៈ ចឹងប្រព័ន្ធយើងគ្រាន់តំរង់ភ្លឺ បិទភ្លឺ មើលភ្លឺ?

ធឿយ ៈ បាទៗ ។

ធានី ៈ ហើយធ្វើអីទៀតទៅ?

ធឿយ ៈ ប៉ុននោះ យើងគ្រាន់ថា គេគ្រាន់តែយើងពូកែខាងតំរង់ដីតំរង់អីទៅណា ហើយមានគេអ្នកបិទ គេអ្នកលើកផ្សេង ។

ធានី ៈ ប៉ុន្តែងាររបស់ពូគេហៅធារាសាស្ត្រអីចឹង?

ធឿយ ៈ បាទ! គេហៅចឹង ។

ធានី ៈ ងារហ្នឹងគេហៅចឹង?

ធឿយ ៈ បាទ! ព្រោះសម័យនោះ គេពិបាកហៅពិបាកស្តាប់ណាស់ វានឹកចង់ហៅម៉េចហៅទៅ ។

ធានី ៈ តែជាទូទៅគេហៅធារាសាស្ត្រចឹង?

ធឿយ ៈ បាទ!

ធានី ៈ ខ្ញុំស្មានថាឈ្មោះសម័យឥឡូវ ធារាសាស្ត្រដឹងតែទឹកហើយ?

ធឿយ ៈ បាទ! ធារាសាស្ត្រ ទឹក ។

ធានី ៈ ចឹងខ្ញុំដឹងតែទឹក ស្មានតែបើកទឹកបើកអីដាក់អាងអីចឹង ។ ហើយចឹងពូនៅហ្នឹង?

ធឿយ ៈ វាចេះរឿងពាក់ព័ន្ធបើកទឹកវាជួនកាល ដល់វាខ្វះកម្លាំង គេហៅខ្ញុំទៅផ្លាស់ដែរវាអត់មានប្រចាំ ចុះណា វាអត់មានជាខ្ញុំប្រចាំរាល់ថ្ងៃទេ ។

ធានី ៈ ប៉ុន្តែពេលខ្វះពូត្រូវកងរបស់ពូ ត្រូវទៅដែរ?

ធឿយ ៈ បាទ! ដល់ពេលណាកន្លែងណាដែលគេថាដោះស្រាយវាមិនចេញ គេហៅខ្ញុំទៅ ។

ធានី ៈ ដោះស្រាយមិនចេញយ៉ាងម៉េច?

ធឿយ ៈ ដោះស្រាយយើងមើលសភាពដី ដូចថាយើងយកទឹកបានមិនបាន ។

ធានី ៈ ហើយពូទៅពូមើលម៉េច ដើម្បីយកទឹកបាន មិនបាន?

ធឿយ ៈ ព្រោះយើងមើលតាមសភាពដីៗទៅ បើសិនណាយើងអាចថាឲ្យគេបើចេញចូលបាន ឲ្យគេធ្វើ អាប្រព័ន្ធធារាសាស្ត្រនឹងបាន យើងឲ្យគេធ្វើទៅ ។

ធានី ៈ យើងមើលដែល?

ធឿយ ៈ បានមើល ។

ធានី ៖ ចឹងយើងអ្នកបញ្ជាឲ្យគេធ្វើអាប្រព័ន្ធហ្នឹងដែរ?

ធឿយ ៖ បាទ! បញ្ជា ។

ធានី ៖ ត្រូវធ្វើដូចថាអាហ្នឹងត្រូវមានចង្អូរទឹកហូរមួយអាហ្នឹងយើងគ្រាន់ប្រាប់គេទៅ យើងមិនបាច់ធ្វើទេ ព្រោះយើងអ្នកប្រាប់គេ?

ធឿយ ៖ បាទ!

ធានី ៖ ហើយការមើលហ្នឹងមើលយ៉ាងម៉េច ពូចេះពីមុនមកឬមួយក៏យ៉ាងម៉េចបានគេឲ្យពូមើលខាងហ្នឹង?

ធឿយ ៖ វាចេះព្រោះអាជាគំនិតនេះ ព្រោះខ្ញុំមិនមែនអ្នកចេះ បើសិនខ្ញុំអ្នកចេះស្លាប់ វាអត់រស់ទេ ប៉ុន្តែគេគិតឃើញខ្ញុំថា មនុស្សល្ងង់ ប៉ុន្តែគេថាវាមានគំនិតៗច្នៃប្រឌិតទៅគេចេះទុកឲ្យរស់ ។

ធានី ៖ ហើយដល់ពេលចឹង ពូមើលដីយ៉ាងម៉េច ដឹងថាបានទឹកនឹងបើកបាន ទឹកនឹងបើកមិនបាន?

ធឿយ ៖ ខ្ញុំមើលតាមសភាពដី ព្រោះដែលខ្ញុំធ្លាប់មើល ខ្ញុំឈរមើលមួយសន្ទុះ ខ្ញុំឈរមើល ខ្ញុំអោនខ្ញុំឈ្ងោកមើលម៉ាសន្ទុះ ខ្ញុំប្រាប់គេថាបាន គឺធ្វើបាន ។ បើសិនណា សម័យនោះ បើសិនណាយើងថាបាន បើគេធ្វើមិនបានយើងក៏ត្រូវស្លាប់ដែរ ។

ធានី ៖ អូ! យើងមើលដែរ?

ធឿយ ៖ បាទ! នោះហើយ គេមិនទុកយើងទេ ។

ធានី ៖ ចឹងពេលពូមើលសភាពដី មើលយ៉ាងម៉េច មើលទីទួល មើលទីមិនទួល មើលដីរាំង ដីជ្រាយយ៉ាងម៉េច?

ធឿយ ៖ បាទ! ព្រោះអាការមើលហ្នឹងវាស្រួល ពេលណាវាបិទអាងខាងលើហើយ អាងខបមាថាអាងនេះវាស្តុបទឹកមកប៉ុនណា ។ យើងថាយើងបិទអាងចេះ យើងស្តុបទឹកមកពីលិច ព្រោះអាងនេះទឹកវាត្រូវច្រលូតទៅកើតហើយ ។

ធានី ៖ ចា៎! ត្រូវហូរទៅចឹង?

ធឿយ ៖ បាទ! ត្រូវហូរទៅកើតហើយ តើយើងទប់របៀបយ៉ាងម៉េច ទឹកត្រូវជះទៅយ៉ាងម៉េចៗ ។

ធានី ៖ ដើម្បីកុំឲ្យបាក់ដីដែរទប់ហ្នឹង?

ធឿយ ៖ បាទៗ ។

ធានី ៖ ចឹងពូចេះយូរហើយ អាមើលហ្នឹង?

ធឿយ ៖ ខ្ញុំចេះសម័យប៉ុន្តែ ។

ធានី ៖ គេបង្រៀនយើង ឬមួយយើងចេះមើលខ្លួនម៉ង?

ធឿយ ៖ អត់មានអ្នកណាបង្រៀនទេ ព្រោះអី!កាលមុនដំបូងគេឲ្យខ្ញុំបិទអាប្រព័ន្ធនេះ ខាងដើងភូមិ ប្រព័ន្ធៗនេះ ។

ធានី ៖ ខាងដើងភូមិយើងនេះ?

ធឿយ ៖ បាទ!

ធានី ៖ ប្រវែងប៉ុន្មានពូ?

ធឿយ ៖ នៅសព្វថ្ងៃ ហ្នឹងអានោះប្រហែលជា១០០០ម៉ែត្រជាង នេះនៅសព្វថ្ងៃ ។ ដល់ពេលឃើញខ្ញុំ ធ្វើទៅ ហើយនឹងចាស់ៗប៉ុន្មាននាក់ទៅ គិតថាដូចថាមានស្នាដៃទៅគេចេះតែទុកទៅ ។ ដល់ ហើយក្រោយផុតនោះ គាត់ជាប់និន្នាការទាហានរត់អស់ ។ ដល់រត់អស់សល់តែខ្ញុំ ។

ធានី ៖ ចឹងអ្នកដែលជាប់ទាហានដូចពូ ធ្វើជាមួយពូដែរ ប៉ុន្តែត្រូវគេរត់អស់ទៅ?

ធឿយ ៖ ធ្វើ បាទ!ខ្លះស្លាប់ គេសម្លាប់ចោល ខ្លះរត់ ។

ធានី ៖ នៅតែពូទេ ព្រោះពូអត់មាន?

ធឿយ ៖ បាទ! ខ្ញុំអត់មានពាក់ព័ន្ធទៅ ខ្ញុំនៅៗបាន ។

ធានី ៖ ចឹងនៅពេលដែលពូនៅធ្វើហ្នឹង ចាំមើលឆ្នាំ ពូថានៅឆ្នាំប៉ុន្មានដែលពូចាប់ផ្តើមធ្វើការងារនៅក្នុង ឃុំ ឆ្នាំប៉ុន្មានដែរពូ ដែល៧៥ខ្មែរក្រហមចូលមកដល់?

ធឿយ ៖ យើង៧៥ចាប់ផ្តើម ហើយដល់ពេល៧៥ ចូលមកដល់យើងអត់កំណត់ថាប៉ុន្មានខែទេ ដែល គេចុះមករៀបចំប្រជុំប្រជាពលរដ្ឋ ។

ធានី ៖ ប្រហែល ចុងឆ្នាំ ដើមឆ្នាំ កណ្តាលឆ្នាំ?

ធឿយ ៖ អឺ! ចុងឆ្នាំៗ៧៥ ។

ធានី ៖ ចុងឆ្នាំ៧៥?

ធឿយ ៖ បាទ!

ធានី ៖ ចឹងបានន័យថាពូចុងឆ្នាំ៧៥ ដែលពូថាពូលើកភ្លូរបស់ហ្នឹងផង បិទទំនប់ផង?

ធឿយ ៖ បាទ! ដែលអានេះបិទអាងដើងគ្រោះនោះ ឆ្នាំ១៩៧៧ទេ ។

ធានី ៖ ចឹងនោះ?

ធឿយ ៖ បាទ! អាងដើងគ្រោះ ។

ធានី ៖ ចឹងពូធ្វើដំបូងពូនៅចុងឆ្នាំ១៩៧៥ ពូគ្រាន់តែធ្វើអ្នកភ្លូរ?

ធឿយ ៖ បាទ! អ្នកក្លួរហើយយើងប្រព័ន្ធភ្លឺ ។

ធានី ៖ លើកភ្លឺ?

ធឿយ ៖ បាទ!

ធានី ៖ ដល់ពេលឆ្នាំប៉ុន្មាន ដែលពូថាទៅចល័តស្រុកនោះ?

ធឿយ ៖ ចល័តស្រុកនៅចុងឆ្នាំ១៩៧៧ ។

ធានី ៖ ចុង៧៧ ចុះអាងលើកអាងដើងគ្រោះនៅឆ្នាំប៉ុន្មាន?

ធឿយ ៖ អានោះ៧៧ដូចគ្នា ប៉ុន្តែយើងលើកពីដើមមក ។

ធានី ៖ ចឹងដើងគ្រោះចុង ហើយដើម?

ធឿយ ៖ ដើម បានសរសេរទុកនឹងជញ្ជាំងលូ ។

ធានី ៖ នៅណាវិញ?

ធឿយ ៖ នៅហ្នឹងអាង ។

ធានី ៖ នៅអាងហ្នឹងពូបានសរសេរដែរ ថាពូបានកសាងវាឡើងនៅឆ្នាំហ្នឹង?

ធឿយ ៖ ខ្ញុំអត់បានសរសេរទេ ប៉ុន្តែអ្នកដែលគេអ្នកនេះគេអ្នកសរសេរទុក ។

ធានី ៖ គេសរសេរថាម៉េច?

ធឿយ ៖ សរសេរដាក់ កសាងឆ្នាំ១៩៧៧ ។

ធានី ៖ ប៉ុន្តែចង់និយាយថា ពូធ្វើការនៅអាងដើងគ្រោះហ្នឹង ចឹងចាប់ផ្ដើមធ្វើពីដំបូងដែលអាងហ្នឹងអត់ ទាន់មានរហូតដល់អាងហ្នឹងមាន?

ធឿយ ៖ បាទ!អាងនោះគេធ្វើ២ដង ធ្វើពី៧៦ម្ដង ៧៦យើងធ្វើតូចទៅស្ដុបទឹកអត់បាន ។ ដល់ក្រោយ មកទៀត ។

ធានី ៖ ៧៧ធ្វើម្ដងទៀត?

ធឿយ ៖ ៧៧ធ្វើម្ដងទៀត បាទ! ។

ធានី ៖ ចឹង៧៦ពូបានចូលរួមធ្វើទេ?

ធឿយ ៖ ចូល៧៦ ខ្ញុំចូលរួមធ្វើ ។

ធានី ៖ ចឹងដំបូងពូធ្វើតាំងពីឆ្នាំ៧៦ អាងដើងគ្រោះហ្នឹង?

ធឿយ ៖ បាទៗ ។

ធានី ៖ ៧៦ ចឹងបានន័យថាខែវស្សាពូលើកភ្លឺស្រែហ្នឹង ដល់ពេលខែប្រាំងដើម៧៦ហ្នឹងពូលើកអាង ដើងគ្រោះហ្នឹងសិន ដល់ពេលខែវស្សាឆ្នាំ៧៦ដដែល ក៏ពូទៅលើកភ្លឺស្រែដដែល?

ធឿយ ៖ បាទ! នៅដដែល ។

ធានី ៖ ដល់លើកភ្លឺស្រែហើយ បានឆ្នាំ៧៧ហ្នឹងបានមកធ្វើដើងគ្រោះម្ដងទៀត?

ធឿយ ៖ បាទ! អានោះកម្លាំងច្រើន កម្លាំងប្រហែលជា៥០០០នាក់ ។

ធានី ៖ អូ! កម្លាំង៥០០០នាក់?

ធឿយ ៖ បាទ!

ធានី ៖ ចុះក្រែងពូថា គេមើលឃើញពូលើកភ្លឺស្រែបានល្អ អាហ្នឹងនៅពេលណាដែរ?

ធឿយ ៖ នៅឆ្នាំ១៩៧៧ ចាប់ពី៧៧មក ។

ធានី ៖ ៧៧ដែរ?

ធឿយ ៖ បាទ!

ធានី ៖ ចឹងបានន័យថាគេឲ្យពូអាភ្លឺស្រែនៅខាងដើងភូមិយើងហើយសិន បានគេបញ្ជូនពីទៅអាងដើងគ្រោះហ្នឹង?

ធឿយ ៖ បាទ! ទៅអាងដើងគ្រោះ ។

ធានី ៖ ចឹង១៩៧៧ លើកភ្លឺស្រែ?

ធឿយ ៖ បាទ! ៧៧ទៅរហូត៧៨នោះឯង ។

ធានី ៖ ភ្លឺស្រែនៅខាងដើងៗភូមិមានស្នាដៃល្អ?

ធឿយ ៖ បាទ! អានោះមិនមែនតែខ្ញុំទេ ប៉ុន្តែអឺ!ម៉ាកងខ្ញុំគេរត់អស់ទៅ ហើយខ្លះក៏ស្លាប់ទៅ ដល់ពេលហ្នឹងទៅវានៅតែខ្ញុំ ។

ធានី ៖ កាលហ្នឹងម៉ាកងពូមានប៉ុន្មាន១០នាក់ហ្នឹង?

ធឿយ ៖ អត់ៗមានច្រើនទេ ។

ធានី ៖ ប៉ុន្មាននាក់កាលហ្នឹង?

ធឿយ ៖ ប្រហែលកាលនោះ ប្រហែលជាចាំមើលប្រហែលជា៥នាក់ ប៉ុន្តែស្លាប់អស់ហើយនៅរស់មួយ នៅរស់ម្នាក់ ។

ធានី ៖ ចឹងពូដំបូងធ្វើជាប្រធានកងនៅអាងធារាសាស្ត្រនៅដើងគ្រោះហ្នឹងសិន?

ធឿយ ៖ អត់ទេ ខ្ញុំអតីតខ្ញុំពីដើមមិញនៅជាកងយុវជនទេ ។

ធានី ៖ កងយុវជន មិនពូថា ចឹងកងយុវជនធម្មតាហើយក្រោយមកទៀត ម៉េចបានពូបានទៅខាងធារាសាស្ត្រ?

ធឿយ ៖ គេដក ។

ធានី ៖ គេដកពីកងយុវជន?

ធឿយ ៖ បាទ! ដល់ពេលខ្ញុំរៀបការប្រពន្ធរួច បានគេបំបែកចេញអស់ ព្រោះប្រៀប ។

ធានី ៖ អឺ! ចឹងពូរៀបគ្រួសារ?

ធឿយ ៖ បាទ! នោះហើយ ។

ធានី ៖ ពូរៀបគ្រួសារនៅឆ្នាំ៧៥?

ធឿយ ៖ ចុងឆ្នាំ៧៥ ។

ធានី ៖ ចុងឆ្នាំ៧៥ ពូរៀបគ្រួសារហើយ គេដកពូចេញពីកងយុវជនហើយ?

ធឿយ ៖ បាទ! ដកចេញ ។

ធានី ៖ ចុងឆ្នាំ១៩៧៥ ក្រោយពីរៀបគ្រួសារ កាលហ្នឹងរៀបគ្រួសារស្ម័គ្រចិត្តខ្លួនឯង ឬម៉េច?

ធឿយ ៖ យើងស្ម័គ្រចិត្តខ្លួនឯង ប៉ុន្តែគេរៀបសម័យនឹងពិបាកណាស់ ៦០គូ ។

ធានី ៖ អ្នកណាគេអ្នកដឹកនាំក្នុងកម្មវិធីហ្នឹង?

ធឿយ ៖ អឺ!តានេះហើយ តាញ៉ែប ប្រធានសង្កាត់នេះ ។

ធានី ៖ ចឹងពូត្រូវដកចេញពីកងចល័តចេញពីកងចល័តយុវជនហ្នឹងហើយ?

ធឿយ ៖ បាទ! គេដកចេញហើយ ។

ធានី ៖ យុវជនឃុំហើយ?

ធឿយ ៖ បាទ!

ធានី ៖ ទៅធ្វើការនៅណាវិញ?

ធឿយ ៖ អឺ! យើងធ្វើការក្នុងឃុំដដែល ។

ធានី ៖ ក្នុងឃុំ ប៉ុន្តែមិនមែនកងចល័តទេ ក្នុងអីទៅ?

ធឿយ ៖ នៅចល័តដូចគ្នា ប៉ុន្តែយើងនៅចល័តឃុំ អត់ៗ ។

ធានី ៖ ចល័តឃុំ លែងយុវជនឃុំហើយ?

ធឿយ ៖ បាទ!

ធានី ៖ ជាចល័តរបស់ឃុំផ្ទាល់វិញ?

ធឿយ ៖ បាទ!

ធានី ៖ អ្នកណាប្រធានទៅ?

ធឿយ ៖ ចល័តឃុំនោះ ។

ធានី ៖ តាញ៉ែប?

ធឿយ ៖ ទេ! ប្រធានចល័តឃុំដូចខ្ញុំថា ប្រាប់លើកមុនមិញ ឈ្មោះឆេង ឆឿននោះ ។

ធានី ៖ ឆេង ឆឿនហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ ចុះប្រធានកងចល័តយុវជនអត់មានទេ?

ធឿយ ៖ កងចល័តយុវជនឈ្មោះនេះ បូរ៉ា ។

ធានី ៖ ចឹងប្រធានកងចល័តឃុំ?

ធឿយ ៖ បាទ! ជី បូរ៉ា ឈ្មោះ ជី បូរ៉ា ។

ធានី ៖ ជី បូរ៉ាជា?

ធឿយ ៖ ប្រធាន ។

ធានី ៖ ប្រធានកងចល័តយុវជន?

ធឿយ ៖ អានេះម៉ាជំនាន់ខ្ញុំ អានេះវាមានក្រោយ វាមានក្រោយវាពិបាកណាស់ គេរៀបច្រើនផ្ទៃច្រើនសារណាស់ ។

ធានី ៖ ចឹងបានន័យថាក្រោយពូរៀបការឆ្នាំ៧៥ហើយ ដើម៧៦ពូចាប់ផ្តើមគេលើកអាង ពូឲ្យគេលើកអាងស្អីគេ អាងទំនប់ជើងគ្រោះ?

ធឿយ ៖ បាទ!

ធានី ៖ ដល់ពេលក្រោយមកទៀតឆ្នាំ៧៧ ក៏ពូបានទៅគេសាកល្បងពូ ឲ្យធ្វើអាទំនប់នៅខាងជើងភូមិហ្នឹង ក៏បានជោគជ័យសម្រេចទៅ?

ធឿយ ៖ អាហ្នឹងមុនៗ អាងជើងគ្រោះ ។

ធានី ៖ ហ្នឹងហើយមុនអាងជើងគ្រោះ ដល់ពេលធ្វើសម្រេចទៅ បានគេឲ្យពូធ្វើជាប្រធានកងខាងធារាសាស្ត្រហ្នឹង?

ធឿយ ៖ បាទ! ខាងធារាសាស្ត្រា ។

ធានី ៖ នៅអាងជើងគ្រោះហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ ប្រចាំឃុំហើយ ធារាសាស្ត្រប្រចាំឃុំយើង?

ធឿយ ៖ អត់ទេ ស្រុកខ្ញុំជាចល័តស្រុក ។

ធានី ៖ ចឹងបានន័យថាពូ កងធារាសាស្ត្រហ្នឹង គឺគេឲ្យខាងស្រុកហើយៗ?

ធឿយ ៖ បាទ! ព្រោះ ។

ធានី ៖  ប៉ុន្តែទៅធ្វើការនៅអាងដើងគ្រោះហ្នឹង?

ធឿយ ៖ បាទ! ព្រោះចេះកាលសម័យនោះយើងវាវិវត្តន៍ច្រើនណាស់ ម្នាក់ៗគេបង្កិលអាខ្វះបាន៣ខែ ៤ខែ វាអត់ទៀងចឹង វាពិបាកណាស់ ។

ធានី ៖  ចឹងដល់ពេលពូឡើងឆ្នាំ៧៧ បានពូថាពូធ្វើនៅហ្នឹងបានសម្រេចហើយ បានទៅអាងត្រពាំងថ្ម ទៀត តំរែតំរង់ភ្ជី?

ធឿយ ៖ បាទ! ទៅត្រពាំងថ្ម ។

ធានី ៖  នៅត្រពាំងថ្មនៅខាងណាត្រពាំងថ្ម បើពូទៅធ្វើការនៅហ្នឹង?

ធឿយ ៖ ខ្ញុំនៅអាជិតស្ពាន នៅខាងត្បូងស្ពានៗ ។

ធានី ៖  ស្ពានធំហ្នឹង?

ធឿយ ៖ បាទ! ស្ពានធំ ។

ធានី ៖  ខាងត្បូងស្ពានៗហ្នឹង ពូធ្វើជាប្រធានខាងតំរង់ មើលភ្ជីស្រែត្រង់មិនត្រង់?

ធឿយ ៖ បាទ! ខ្ញុំធ្វើប្រធាន ។

ធានី ៖  ចឹងអ្នកដូចពូហ្នឹងមានច្រើននាក់ទេ?

ធឿយ ៖ វា១០នាក់ ។

ធានី ៖  ១០នាក់ហ្នឹង?

ធឿយ ៖ កាលនោះវាម៉ាតំបន់ នៅអាងត្រពាំងថ្ម វាមានចំណុះនៅអាងត្រពាំងថ្មមនុស្សម៉ាតំបន់ ។

ធានី ៖  មនុស្សម៉ាតំបន់?

ធឿយ ៖ បាទ! យើងនោះតំបន់៥ ។

ធានី ៖  ចាំ! មនុស្សម៉ាតំបន់៥ហ្នឹង វាមាន១០នាក់ដែលខាងធារាសាស្ត្រដូចពូហ្នឹង?

ធឿយ ៖ វាចេះ មនុស្សម៉ាតំបន់៥នេះ ពេលណានេះគេជ្រើសរើសពួកអ្នកមានស្នាដៃខាងយើងតំរង់ បានត្រង់ ។ ដល់ពេលវាច្រើនសហករណ៍រួមគ្នាទៅ ដល់ពេលគេជ្រើសរើសទៅជាប់ខ្ញុំៗទៅ គេអត់មានអ្នកណាបញ្ចូលទេ តែខ្ញុំ ហើយនឹងប្រជាពលរដ្ឋនៅភូមិកំណើតរបស់ខ្ញុំ១០នាក់ អត់ ឲ្យមានខាងអ្នកផ្សេងមកលាយទេ ។

ធានី ៖  អ្នកផ្សេងមកទេ?

ធឿយ ៖ បាទ!

ធានី ៖  ចឹងពូប្រធានហើយអ្នក១០នាក់ទៀតជាកូនចៅរបស់ពូហ្នឹង?

ធឿយ ៖ ជាកូនចៅ ។

ធានី ៖ គឺធ្វើការផ្សារហ្នឹងទាំងអស់?

ធឿយ ៖ បាទ!

ធានី ៖ ប្រធានខាងតំរង់នៅខាងត្រពាំងថ្មហ្នឹងដែរ?

ធឿយ ៖ បាទ!

ធានី ៖ ប៉ុន្តែគេហៅចូលចល័ត អេ!ចូលធារាសាស្ត្រាតំបន់៥វិញហើយ ពេលហ្នឹង?

ធឿយ ៖ បាទ! ទៅនោះចូលតំបន់៥ហើយ ព្រោះកន្លែងនោះកន្លែងរួមតំបន់៥ ។

ធានី ៖ ចឹងពូកន្លែងហ្នឹងពូឡើងប្រធានម៉ាតង់ទៀតហើយមែនទេ?

ធឿយ ៖ បាទ!

ធានី ៖ ឡើងជាប្រធានធារាសាស្ត្រដែរ តែប្រចាំតំបន់វិញ?

ធឿយ ៖ បាទ! ប៉ុន្តែកាលនោះគេច្រើនហៅចេះ គេថាយើងសុរិយោដី ។

ធានី ៖ អូ! ខាងសុរិយោដី?

ធឿយ ៖ បាទ! ប៉ុន្តែយើងវាមិនច្បាស់លាស់ទេ ប៉ុន្តែសម័យនោះគេមិនយកអ្នកចេះទេ ។

ធានី ៖ ត្រូវហើយពូ ដូចថាគេប្រើពាក្យអី ពូប្រើពាក្យហ្នឹងម៉ង បានខ្ញុំដឹងថាអាហ្នឹងចឹង ។

ធឿយ ៖ បាទ! នោះហើយ ។

ធានី ៖ ចឹងសុរិយោដីហ្នឹង១០នាក់ ពូប្រធាន អ្នកណាអនុប្រធាន?

ធឿយ ៖ អនុប្រធានអត់មានទេ ។

ធានី ៖ ចឹងពូប្រធានម្នាក់ឯង?

ធឿយ ៖ បាទ! ប៉ុនោះកូនចៅខ្លះ ។

ធានី ៖ ពូប្រធាន ហើយដូចថាឲ្យកូនចៅពូធ្វើការផ្សារអីខ្លះទៅ?

ធឿយ ៖ ខ្ញុំគ្រាន់តែមានតួនាទីថា កូនចៅរបស់ខ្ញុំមានតែគេសម័យនោះគេប្រើបង្គោល គេប្រើចំរឹង ហើយឲ្យគេដើរបោះទៅ ខ្ញុំអ្នកតំរង់ ។

ធានី ៖ អឺ! ពូអ្នកតំរង់មើលត្រង់ហើយ?

ធឿយ ៖ បាទ! ខ្ញុំៗអត់មាននេះទេ ខ្ញុំគ្រាន់តែអ្នកតំរង់សុទ្ធ ព្រោះឲ្យអាកូនចៅ១០នាក់ហ្នឹងគេអ្នកដើរបោះបង្គោល ។

ធានី ៖ តំរង់មើលតែគេបោះបង្គោលអត់ត្រង់ យើងបោះម្តងទៀត?

ធឿយ ៖ បាទ! បើបោះឃើញថាដី១គីឡូ ២គីឡូ យើងអត់មានឃើញស្អី ឃើញតែបង្គោល១ នោះបានត្រង់ៗ អត់មាន ឧបមាថាបោះទៅបង្គោលអត់មានខុសគ្នាទេ មើលថាបង្គោល១០០បង្គោលចេះ មើលទៅឃើញតែ១ អត់មានឃើញបង្គោល ។

ធានី ៖ អាហ្នឹងបានហៅថាត្រង់?

ធឿយ ៖ បាទ!នោះហើយ ។

ធានី ៖ បើហ៊ានតែវៀចតិច?

ធឿយ ៖ អត់បានទេ ។

ធានី ៖ ហើយអ្នកណាគេលើ ជាប្រធានរបស់ពូ បន្ទាប់ពីពូទៅ?

ធឿយ ៖ ឆេង ឆឿន ។

ធានី ៖ ឆេង ឆឿនហ្នឹង?

ធឿយ ៖ ឆេង ឆឿនដដែលនោះឯង ។

ធានី ៖ ចឹងឆេង ឆឿនហ្នឹងឡើងទៅតំបន់ទៀត ដំបូងចល័តឃុំទេ?

ធឿយ ៖ បាទ! ឡើងទៅនោះទៀត ។

ធានី ៖ ឆេង ឆឿន ឡើងតំបន់?

ធឿយ ៖ គាត់ទៅនោះ គាត់ជាចល័តខាងស្រុកទេ ខាងតំបន់គេផ្សេង ។

ធានី ៖ ស្រុកដែរ ប៉ុន្តែមកធ្វើការនៅហ្នឹង?

ធឿយ ៖ បាទ! ព្រោះខ្ញុំក៏ចល័តស្រុកដូចគ្នា ប៉ុន្តែខាងតំបន់គេអ្នកទាញឲ្យទៅធ្វើការជាមួយ ។

ធានី ៖ ព្រោះពូប្រាប់ថាភ្ជួន បានជាចល័តស្រុក?

ធឿយ ៖ បាទ!

ធានី ៖ ឆេង ឆឿន ត្រឹមឃុំទេ?

ធឿយ ៖ បាទ! ដែលនៅនេះឃុំ ។

ធានី ៖ ចា៎! ដល់ពេលឡើងទៅនោះ ឡើងតំបន់?

ធឿយ ៖ ដល់នោះស្រុក ។

ធានី ៖ អ៎!ស្រុក ។

ធឿយ ៖ ដល់ពេលគេហៅធ្វើការ ពួកតំបន់ហៅធ្វើការ វាពិបាកណាស់ ពួកនេះវារៀបចំ វាច្រើន ។

ធានី ៖ ឡើងវិល?

ធឿយ ៖ បាទ! នោះហើយ ។

ធានី ៖ ឲ្យតែអ្នកណាបញ្ជាចេះតែទៅៗ?

ធឿយ ៖ បាទ! គេបញ្ជាវាពិបាករៀបរាប់ណាស់ អានេះដែលខ្ញុំដកពិសោធន៍ផ្ទាល់ខ្លួនឯង ។

ធានី ៖ ចឹងពេលពូទៅដល់ត្រពាំងថ្មហ្នឹង ពេលពូទៅដល់ គេធ្វើហើយអស់ហើយ ឬក៏នៅទេ?

ធឿយ ៖ អាងនោះ គេធ្វើរួចអស់ហើយ ។

ធានី ៖ គេសម្ពោធន៍នៅពេលណាដឹងទេ អាងត្រពាំងថ្ម?

ធឿយ ៖ គេសម្ពោធន៍ខ្ញុំអត់បានដឹងផង ។

ធានី ៖ គ្រាន់តែបានដឹងថាអាងហ្នឹងគេធ្វើហើយអស់ហើយ?

ធឿយ ៖ បាទ! គេធ្វើស់ហើយ ។

ធានី ៖ ពូដឹងថាប្រវែងវាប៉ុន្មានខ្នង ទទឹងប៉ុន្មាន ជម្រៅប៉ុន្មានអី?

ធឿយ ៖ ខ្ញុំអត់ដឹង ប្រហែលជា បើបណ្ដោយប្រហែលជាប៉ុន្មាន ខ្ញុំមិនសូវដឹងច្បាស់ផង ។

ធានី ៖ ហើយដឹងថាអ្នកណាគេអ្នកកសាងត្រពាំងហ្នឹង ត្រពាំងថ្មហ្នឹង អ្នកណាគេអ្នកកសាង?

ធឿយ ៖ ត្រពាំងថ្មហ្នឹងខាងតំបន់គេអ្នករៀបចំ ។

ធានី ៖ ដឹងឈ្មោះប្រធានតំបន់ហ្នឹងទេ?

ធឿយ ៖ អឺ!នេះហើយគណៈតំបន់ឈ្មោះស្អីទេ ខ្ញុំភ្លេចឈ្មោះគណៈតំបន់ភ្លេចបាត់ ព្រោះខ្ញុំៗធ្លាប់ដើរជុំដែរ ភ្លេចឈ្មោះ ។

ធានី ៖ ស្រី ឬប្រុស?

ធឿយ ៖ ប្រុស ។

ធានី ៖ ប្រុស ហ៊ឹង ជៀល?

ធឿយ ៖ តាជៀលៗ ។

ធានី ៖ តាជៀល?

ធឿយ ៖ បាទ!

ធានី ៖ តាជៀល គណៈតំបន់៥?

ធឿយ ៖ បាទ!

ធានី ៖ ពូស្គាល់តាជៀល?

ធឿយ ៖ តាជៀល ។

ធានី ៖ ពូដឹងថាតាជៀលហ្នឹងអ្នកណាគេទេ?

ធឿយ ៖ បាទ!

ធានី ៖ ត្រូវជាអីហ្នឹង ប្រធានតំបន់?

ធឿយ ៖ តាជៀលហ្នឹងប្រធានតំបន់៥ គេអ្នកចុះគ្រប់គ្រង ។

ធានី ៖ ដឹងថាពីមុនមកឪពុកម្តាយគាត់ធ្វើអីពីមុនៗមកដឹងទេ?

ធឿយ ៖ អត់ដឹងទេ ដឹងប្រវត្តិដឹងគេមកពីណាផង ។

ធានី ៖ ចុះក្រៅពីតាជៀលមានអ្នកណាផ្សេងទៀតទៅ?

ធឿយ ៖ ក្រៅពីតាជៀល វាមានមកខាងថងស្រុកខាងអីខ្ញុំអត់សូវស្គាល់ ។

ធានី ៖ អត់សូវស្គាល់ៗតែតាជៀលមួយ?

ធឿយ ៖ បាទ! ហើយសម័យនោះ យើងមិនសូវហ៊ានស្គាល់គេប៉ុន្មានទេ បើដូចថាតាជៀល គាត់ធ្លាប់ហៅខ្ញុំដើរជុំទៅ ខ្ញុំស្គាល់ ។ ដល់ផុតពីនោះ ខ្ញុំមិនសូវស្គាល់ប៉ុន្មានទេ ។

ធានី ៖ កាលនោះ ម៉េចបានគាត់ហៅពូដើរជុំចឹង?

ធឿយ ៖ ព្រោះខ្ញុំខាងមើលដីមើលអីហ្នឹង ហៅដើរមើលជុំ ។

ធានី ៖ តែពេលហ្នឹងត្រពាំងថ្មធ្វើហើយៗ?

ធឿយ ៖ បាទ!

ធានី ៖ ចុះពូថាឪពុកពូស្លាប់នៅឆ្នាំ៧៧ដែរនោះ?

ធឿយ ៖ បាទ!

ធានី ៖ ពេលហ្នឹង ពេលដែលពូទៅត្រពាំងថ្មហើយ ឬក៏យ៉ាងម៉េច?

ធឿយ ៖ បាទ! អត់ទាន់បានទៅទេ នៅក្រោយ ។

ធានី ៖ ម៉េចបានគេយកគាត់ទៅសម្លាប់អីចឹង?

ធឿយ ៖ ព្រោះគាត់ជាអតីតទាហានផង ជំទុកលេខ១ផងទៅ ។

ធានី ៖ ចង់សួរពូថា ចុះកាលមុនដំបូងម៉េចអត់អី ដល់ពេលក្រោយឆ្នាំ៧៧បានគេចាប់គាត់?

ធឿយ ៖ ព្រោះពួកនេះវាសម្លាប់ វាអត់មានតែក! អត់ទាន់សម្លាប់ភ្លាមៗទេ បើដូចពួកខ្ញុំចេះវាដូចថាវា នៅតាមដានៗតើសកម្មភាពយ៉ាងម៉េចៗទៅណា ។ ប៉ុន្តែដល់ក្រោយៗមកទៅ ឪពុកខ្ញុំគាត់ អត់ធ្វើការប្រហែសធ្វើការទេ គាត់បម្រើគេល្អណាស់ ។ ប៉ុន្តែចៀសអត់ផុតពីគេសម្លាប់ ដោយសារៗគេដូរកម្មាភិបាល ។

ធានី ៖ គេដូរពេលណាពូ?

ធឿយ ៖ បាទ! គេដូរៗតាសាំដែរ ។

ធានី ៖ អឺ! ដូរតាសាំទៅណា?

ធឿយ ៖ បាទ! ដូរតាញ៉ៅបមក ដូរតាសាំុចូល ។

ធានី ៖ អឺ! ប្ដូរពីតាញ៉ៅប?

ធឿយ ៖ មកតាសាំុ ។

ធានី ៖ ទៅតាសាំុ?

ធឿយ ៖ បាទ!

ធានី ៖ តាសាំុហ្នឹងចូលមកសម្លាប់ឪពុកពូបណ្ដោយ?

ធឿយ ៖ បាទ!

ធានី ៖ ចុះពូអត់អាចជួយការពារគាត់បានទេ?

ធឿយ ៖ អត់បានទេ អត់មាន បើសិនខ្ញុំទៅការពារស្លាប់ទាំងអស់គ្នា ព្រោះខ្ញុំឃើញដាក់ស្ដែងនៅភូមិក្បាលទន្សោងៗខាងលិចនេះ ឈ្មោះតាលាភ អានោះគេចាប់កូនមកៗដល់អាពេលគាត់តាម មកធានា តាមមកសុំ អានោះគេសម្លាប់ចោលទាំងអស់ ។

ធានី ៖ អូ! អត់ទុកឲ្យរស់សោះ?

ធឿយ ៖ បាទ! អត់ទុកឲ្យរស់ទេ ។

ធានី ៖ ពូបានដឹងឃើញដាក់ស្ដែងទេ គេសម្លាប់ហ្នឹង?

ធឿយ ៖ អត់បានឃើញទេ គ្រាន់ដឹងថា ឃើញគេចាប់យកទៅ ។

ធានី ៖ ចាប់យកទៅណា ពូដឹងទេ?

ធឿយ ៖ គេចាប់បញ្ជូនយកទៅត្បូង ។

ធានី ៖ ទៅកន្លែងណា គេហៅកន្លែងអីកន្លែងហ្នឹង?

ធឿយ ៖ អឺ! បើពួកខ្ញុំ បើតាមដែលខ្ញុំកាកស្មាន ដែលខ្ញុំរាប់ប្រហែលជាគេយកទៅសម្លាប់នៅបន្ទាយចាស់ថ្មពួក ខាងជើងថ្មពួក បន្ទាយទាហាន ។

ធានី ៖ នៅបន្ទាយ ក្នុងបន្ទាយហ្នឹងម៉ង?

ធឿយ ៖ បាទ! ក្រៅបន្ទាយ ។

ធានី ៖ បន្ទាយហ្នឹង កន្លែងគេសម្លាប់មនុស្ស ឬក៏កន្លែងយ៉ាងម៉េចបានគេយកទៅសម្លាប់?

ធឿយ ៖ បន្ទាយនោះ វាកន្លែងសម្លាប់ៗមនុស្សច្រើន វាជីករណ្ដៅ ក្នុងម៉ារណ្ដៅ៥០-៦០នាក់ ។

ធានី ៖ ចុះពូក្រោយមក ក្រោយបែក៧៩ ដែលធ្លាប់ទៅជីកកកាយរកធាតុឪពុក?

ធឿយ ៖ មិនដឹងជារកយ៉ាងម៉េច ដល់ខ្មោចច្រើនចុះយើងមិនដឹងរកថាយ៉ាងម៉េចឃើញ ។

ធានី ៖ តែដឹងថាគាត់ស្លាប់នៅហ្នឹង?

ធឿយ ៖ បាទ! ដឹង ។

ធានី ៖ តែធ្លាប់ធ្វើបុណ្យៗ នៅហ្នឹងអីទេ?

ធឿយ ៖ យើងធ្លាប់ធ្វើបុណ្យជូនគាត់ដែរ ។

ធានី ៖ ចឹងចុះដូចថាពូមិនជាកូនរបស់គាត់ ចឹងគេថាជាប់និន្នាការអីដែរ គេអត់ថាអី?

ធឿយ ៖ បាទ! ជាប់ ប៉ុន្តែគេនៅតាមដាន ។

ធានី ៖ គេនៅតាមដាន?

ធឿយ ៖ បាទ! ប៉ុន្តែដូចខ្ញុំ ដូចជាថាខ្ញុំមាននិស្ស័យល្អចេះ គេចាប់ដែរ ។

ធានី ៖ ចាប់ពេលណា?

ធឿយ ៖ គេហៅយើងទៅកសាងអីទៅ គេថាយើងជាប់និន្នាការអីទៅ ដល់ពេលនេះ គេមានអ្នកដែលធ្វើការហ្នឹងគេជួយ ។ គេថាជួយថាមនុស្សនេះមនុស្សល្អទេ ដោយសារអ្នកដែលពាក់ព័ន្ធហ្នឹងវា ចេះតែចោទ ហើយទៅដល់នេះគេលែងមកវិញ ។ គេចាប់ខ្ញុំនៅចុងឆ្នាំ៧៧ ប៉ុនខ្ញុំអត់ចាំខែ ទេ ។

ធានី ៖ ១៩៧៧ ចាប់ពូ?

ធឿយ ៖ បាទ!

ធានី ៖ អ្នកណាមកចាប់?

ធឿយ ៖ តាសាំុហ្នឹងឯង ។

ធានី ៖ តាសាំុមកចាប់ផ្ទាល់តែម្តង?

ធឿយ ៖ ទេ! កូនចៅគេ ។

ធានី ៖ តាសាំុបញ្ជាឲ្យមកចាប់ពូ?

ធឿយ ៖ បាទ!

ធានី ៖ ចាប់យកទៅណាទៅ?

ធឿយ ៖ ទៅកន្លែងសហករណ៍គេ ។

ធានី ៖ សហករណ៍នៅណាទៅ?

ធឿយ ៖ សហករណ៍នៅសាលារៀនបន្ទាយឆ្មារ ។

ធានី ៖ នៅសាលាបន្ទាយឆ្មារ?

ធឿយ ៖ បាទ! គេចោទខ្ញុំថាចោរ ។

ធានី ៖ ម៉េចចោទពូថាចោរចឹង?

ធឿយ ៖ ដោយសារគេចាប់បានអាអ្នកផ្សេងទៅ គេចោទខ្ញុំ ។

ធានី ៖ គេចាប់បានអ្នកណាគេ?

ធឿយ ៖ ដែលចាប់បាននោះ ចាប់បានឈ្មោះស្តីទេ ភ្លេច សេន ។

ធានី ៖ សេន ហ្នឹង?

ធឿយ ៖ បាទ! ឈ្មោះអាសេន គេចាប់បានទៅ ដល់ពេលគេវ៉ៃសួរចម្លើយ វាចោទដាក់ឈ្មោះខ្ញុំបាន ចេះ ។

ធានី ៖ ដាក់ឈ្មោះពូចឹង?

ធឿយ ៖ បាទ!

ធានី ៖ ចឹងពេលហ្នឹងឪពុកពូស្លាប់ហើយ?

ធឿយ ៖ ស្លាប់ហើយ ។

ធានី ៖ ដាក់ឈ្មោះពូរឿងអី រឿងថាចោរហ្នឹង?

ធឿយ ៖ ដែលថាចោរហ្នឹង ។

ធានី ៖ ចឹងសេនហ្នឹងចោរដែរ?

ធឿយ ៖ សេនហ្នឹងចោរៗ ។

ធានី ៖ ហើយសេនហ្នឹង ថាពូចូលរួមគំនិតធ្វើចោរដែរ?

ធឿយ ៖ បាទ!

ធានី ៖ ចោរអីគេ ចោរលួចអី?

ធឿយ ៖ ចោរអាលួច យើងលួចដំឡូង លួស្ករ លួចល្ពៅលួចអីហ្នឹង អានឹងលួចស្លាប់ដូចគ្នា ។

ធានី ៖ គាត់លួចអីគេ?

ធឿយ ៖ គាត់លួចដំឡូង ។

ធានី ៖ លួចដំឡូងគេទាន់?

ធឿយ ៖ បាទ! ហ្នឹងសម្លាប់ចោលដូចតែគ្នា ។

ធានី ៖ អឺ! ដល់ពេលលួចដំឡូងគេចាប់បាន ក៏គេឆ្លើយថាពូ?

ធឿយ ៖ បាទ! ឆ្លើយ ។

ធានី ៖ ហើយពេលពូទៅដល់ គេចាប់ពូវ៉ៃដែរអត់ទេ?

ធឿយ ៖ អត់បានវ៉ៃទេ ដល់ចាប់ទៅវាមានអ្នកធ្វើការនៅនោះទៅ ដល់គេសាកសួរទៅ គាត់ថាមនុស្ស នេះមនុស្សល្អទេ ព្រោះមនុស្សនេះបម្រើការងារជូនបក្សមកល្អណាស់ តាំងពីដើមមកចឹងណា មិនគួរយកគាត់មកចោទចេះទេ ។ ដល់ពេលគណៈសង្កាត់គេពិគ្រោះទៅគេឲ្យមកវិញ ។

ធានី ៖ ចឹងអ្នកណាគេអ្នកធានាពូៗចាំទេ?

ធឿយ ៖ អឺ! ឈ្មោះណាត់ នេះហាក់ ។

ធានី ៖ ឈ្មោះហាក់ គាត់ហ្នឹងងាររជាអីគេ?

ធឿយ ៖ នោះគេដើមមិញគេហៅខាងសេដ្ឋកិច្ច សព្វថ្ងៃគេទៅអាមេរិច ។

ធានី ៖ ដឹងដែរ ពូធ្លាប់ជួនដំណឹងពីដែរ?

ធឿយ ៖ បាទ! ហ្នឹងគេទៅអាមេរិច នោះឯងគេអ្នកជួយអះអាង ។

ធានី ៖ ជួយនិយាយ?

ធឿយ ៖ បាទ! ជួយនិយាយក្នុងគណៈសង្កាត់នោះ ។

ធានី ៖ ដល់ពេលគេតាមដានមុន ៗ ចុះពូជាប់និន្នាការឪពុកអីក៏គេអត់ថាអីដែរ បងប្អូនពូអត់អីវិញ?

ធឿយ ៖ អត់អីទេ ។

ធានី ៖ គេចាប់តែឪពុកពូមួយហើយៗ?

ធឿយ ៖ បាទ!

ធានី ៖ អ្នកផ្សេងទៀតក៏ចឹងដែរចឹង បើសិនជា?

ធឿយ ៖ បាទ! អ្នកផ្សេងដូចគ្នាចេះ បើសិនតើគេតាមដាន ក្រុមគ្រួសារដែលតាមដានយើងធ្វើសកម្មភាព មានគេចាប់យកទៅសម្លាប់ចោលខ្លះ ។

ធានី ៖ ចឹងបើសិនជាក្រុមគ្រួសារហ្នឹងដែលចូលរួមជាមួយហ្នឹងក៏គេចាប់ដែរ?

ធឿយ ៖ បាទ!

ធានី ៖ ចឹងយើងធ្វើម៉េចដឹង ថាគេចូលរួមមិនចូលរួម ដូចពូចឹងធ្វើម៉េចគេដឹងថាពូចូលរួមមិនចូល បើនៅផ្ទះជាមួយគ្នាចឹង?

ធឿយ ៖ គេតានដាន ។

ធានី ៖ គេតាមដានយ៉ាងម៉េច?

ធឿយ ៖ គេតាមដាន គេមើលសកម្មភាពយើងធ្វើការ ដូចថាយើងធ្វើការមិនសូវយកចិត្តទុកដាក់ ហើយយើងធ្វើការដូចថាឪពុកម្ដាយយើងស្លាប់ យើងមានអារម្មណ៍អត់ល្អទៅ អត់សូវទៅធ្វើការទៅយើងចេះតែកុហកគេថាឈឺ ថាគ្រុនអីទៅ គេចេះតាមដានចេះឯង ។

ធានី ៖  ចឹងបានគេថាយើងមានសតិអារម្មណ៍អីចឹង?

ធឿយ ៖ បាទ! អាហ្នឹងអានេះ ខ្ញុំនិយាយពីតំបន់ខ្ញុំខាងនេះ គឺជាក់ស្តែងចឹងឯង ។

ធានី ៖  ចឹងបន្ទាប់មកទៀត បានពូធ្វើការនៅត្រពាំងថ្មនឹងរហូត ឬក៏ម៉េចពូ?

ធឿយ ៖ អត់ទេ គេបញ្ជូនមកវិញ ។

ធានី ៖  បញ្ជូនមកវិញនៅឆ្នាំប៉ុន្មានទៅ?

ធឿយ ៖ បញ្ជូនមកវិញនៅដើមឆ្នាំ៧៨ ។

ធានី ៖  ដើមឆ្នាំ៧៨ ពូមកវិញធ្វើអីគេ?

ធឿយ ៖ បាទ! ឲ្យមកនៅធ្វើស្រែវិញដដែល ។

ធានី ៖  ធ្វើស្រែធម្មតា?

ធឿយ ៖ បាទ! ធ្វើស្រែប៉ុន្តែ ។

ធានី ៖  ធ្វើជាប្រធានគេ ឬក៏ម៉េច?

ធឿយ ៖ អត់ទេ នៅធ្វើស្រែ ខ្ញុំនៅខាងនេះវិញដដែល នៅតែខាងប្រព័ន្ធធារាសាស្ត្រ ដដែល ។

ធានី ៖  អូ! ពូធ្វើប្រធានដដែល?

ធឿយ ៖ បាទ! នៅតែចឹង ។

ធានី ៖  តែពូអត់ធ្វើស្រែទេ គ្រាប់ពូមើលខាងតំរង់ភ្លឺ តំរង់អីហ្នឹង បិទទំនប់ បិទអីហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖  យើងផ្សារមកពីណា យើងត្រឡប់ទៅវិញ កន្លែងហ្នឹងផ្សារយើងដដែល?

ធឿយ ៖ បាទ! ទោះបីជាគេដូរមកពីចល័តស្រុក មកតំបន់ មកពីឃុំវិញយ៉ាងណាឲ្យតែយើងហ៊ានធ្វើ ។

ធានី ៖  តែក្រុមកូនចៅរបស់ពូមាន១០នាក់ហ្នឹងឯង?

ធឿយ ៖ បាទ! ប៉ុន្តែកូនចៅយើងមានដូរ ។

ធានី ៖  មានដូរ?

ធឿយ ៖ បាទ! ឧបមាថាដូចឯនោះ យើងថាត្រូវដូរក៏ដូរចេញទៅ ។

ធានី ៖  ហេតុអីពូ?

ធឿយ ៖ ព្រោះ ឧបមាថាខ្ញុំមកចេះ គេបញ្ជូនមកវិញចេះ ខ្ញុំគេឲ្យទៅចូលអាកងផ្សេងចេះ ខ្ញុំទៅរើស អាកងផ្សេងនោះ ។

ធានី ៖  ហេតុអីយើងមិនមែនរើសនៅស្រុកភូមិយើង ក្រែងពូមុនថារើសយកពីស្រុកយើង?

ធឿយ ៖ ស្រុកភូមិយើង ប៉ុន្តែយើងយកមនុស្សផ្សេងទៀត ។

ធានី ៖ ហេតុអី អ្នកចាស់ហ្នឹងទៅណាវិញទៅ?

ធឿយ ៖ គេដកឲ្យទៅធ្វើការផ្សេងទៀត ។

ធានី ៖ អត់ដឹងគេដកយកទៅណាទៅណែ?

ធឿយ ៖ អត់ទេធ្វើស្រែធ្វើចំការហ្នឹងឯង អត់មាន ។

ធានី ៖ តែមានបាត់ទេ តែមានគេដកទៅបាត់ខ្លួនទេ?

ធឿយ ៖ អត់ទេ អត់មានសម្លាប់ទេ ។

ធានី ៖ អត់មាន គ្រាន់តែដូរការងារ?

ធឿយ ៖ បាទ! ព្រោះខ្ញុំៗជឿតាមកាលសម័យនោះខ្សែពូជពង្សខ្ញុំជាប់ធ្វើការទាំងអស់ តាៗខ្ញុំគាត់មេឃុំ ។

ធានី ៖ មេឃុំសម័យខ្មែរក្រហម ឬក៏មិនហ្នឹង?

ធឿយ ៖ អត់ទេ លន់ នល់ ។ បាទ! ដល់ពុកខ្ញុំនេះជិតុកលេខ១ ដល់ប្អូនថ្លៃពុកខ្ញុំនេះស្មៀន វាជាប់ទាំងអស់ ។ ដល់ពេលដែលមេឃុំដែលថានោះ គាត់រត់ទៅថៃ គាត់ហៅខ្ញុំទៅណែនាំឲ្យខ្ញុំកសាងខ្លួន ហើយខ្ញុំចេះធ្វើតាមគាត់ទៅ បានខ្ញុំបានរស់ចេះឯង ។

ធានី ៖ មេឃុំដែលរត់ទៅថៃមុនទៅហ្នឹង គាត់ណែនាំចឹង?

ធឿយ ៖ បាទ!

ធានី ៖ ហើយគាត់រត់ទៅធ្វើអី តាពូ?

ធឿយ ៖ បើមិនរត់ទៅគេសម្លាប់ ។

ធានី ៖ ចឹងរាល់ថ្ងៃគាត់នៅរស់ទេ?

ធឿយ ៖ គាត់ស្លាប់ហើយ ។

ធានី ៖ គាត់ស្លាប់មិនមែនសម័យអាពត?

ធឿយ ៖ អត់ទេ ទើបស្លាប់ប៉ុន្មានឆ្នាំ ២-៣ឆ្នាំ ។

ធានី ៖ តាពូឈ្មោះអីគេ?

ធឿយ ៖ តានេះ ប៊ូ នាវ ។

ធានី ៖ ប៊ូ នាវ?

ធឿយ ៖ បាទ!

ធានី ៖ គាត់ដឹងសម័យខ្មែរក្រហមចូលមកដល់ គាត់រត់ទៅថៃមុន?

ធឿយ ៖ បាទ! គាត់នៅខាងប្រព័ន្ធភ្លឺជាមួយខ្ញុំហ្នឹងឯង ប៉ុន្តែដល់ពេលគាត់រៀបរត់ទៅ គាត់ជួបខ្ញុំ គាត់ផ្តែផ្តាំ ។

ធានី ៖ ឆ្នាំប៉ុន្មាន គាត់រៀបរត់?

ធឿយ ៖ អឺ! ៧៧ ។

ធានី ៖ តែពេលហ្នឹងពូនៅត្រឹមជាមួយគាត់ដែរ ដែលពូថាអ្នកខ្លះរត់ អ្នកខ្លះស្លាប់ហ្នឹង?

ធឿយ ៖ បាទ! នៅជាមួយគ្នា ប៉ុន្តែកាលហ្នឹង អាខ្លះរត់ គាត់រត់ផុត អាខ្លះងាប់គេចាប់សម្លាប់ចោល ។ ខ្ញុំជាប់ដូចគ្នា ប៉ុន្តែគេលើកលែងឲ្យ ថាដូចខ្ញុំលាក់ៗពីប្រវត្តិ ហើយបងថ្លៃរត់ៗ ដល់ពេល គាត់រត់ទៅ គាត់នាំខ្ញុំទៅៗអត់ទៅ ដល់ពេលនេះខ្ញុំលាក់ៗដល់ម៉ោង៩យប់ ខ្ញុំទៅរាយការណ៍ ឲ្យកម្មាភិបាលទៅ គេថាខ្ញុំសុំគំនុំជាមួយអ្នករត់ ដល់ហើយគេចាប់ខ្ញុំម៉ាសារទៀត ។

ធានី ៖ បងប្រុស ហើយបងថ្លៃ?

ធឿយ ៖ បងៗថ្លៃ ។

ធានី ៖ ឈ្មោះអីគេពូ?

ធឿយ ៖ ឈ្មោះ ចាន់ ដើយ ។

ធានី ៖ ស្មៀនហ្នឹង?

ធឿយ ៖ អត់ទេ តែស្មៀនហ្នឹង គាត់ឈ្មោះ គាយ៉ុង គាត់ស្លាប់ហើយ ប៉ុលពតសម្លាប់ ។

ធានី ៖ ពេលដែលរត់ហ្នឹងដែរ?

ធឿយ ៖ អត់បានរត់ទេ គេចាប់សម្លាប់ ។

ធានី ៖ គេចាប់សម្លាប់នៅភូមិយើង?

ធឿយ ៖ បាទ! នោះហើយ វាច្រើនណាស់ ។

ធានី ៖ ចឹងមិញចាន់អីគេចាន់?

ធឿយ ៖ ចាន់ ចើយ ។

ធានី ៖ ចាន់ ចើយហ្នឹង គាត់ចង់រត់ទៅថៃ?

ធឿយ ៖ បាទ!

ធានី ៖ ម៉េចចឹងពូ?

ធឿយ ៖ គាត់ទាហាន ។

ធានី ៖ អូ! គាត់ទាហានលន់ នល់?

ធឿយ ៖ បាទ!

ធានី ៖ ដល់ពេលហ្នឹងគាត់ចង់រត់ទៅថៃ ពូអត់ហ៊ានរាយការណ៍ទេ ដល់ពេលគាត់រត់ទៅបាត់ហើយបាន រាយការណ៍?

ធឿយ ៖ បាទ! គាត់ទៅផុត ។

ធានី ៖ ទៅផុត ដល់ពេលរាយការណ៍ទៅ គេចាប់ពូទៅវិញ?

ធឿយ ៖ បាទ! គេចោទថាខ្ញុំអ្នកជួយខ្ញុំលាក់ ដល់ពេលនេះខ្ញុំឆ្លើយបានរួចខ្លួន ខ្ញុំឆ្លើយថា ខ្ញុំអត់ដឹងគាត់ទេ ថាគាត់ប្រាប់ខ្ញុំថាទៅមុជទឹក ដល់ពេលបាត់គាត់យូរខ្ញុំរាយការណ៍ ។ ដល់នេះបានខ្ញុំរួចខ្លួនទៀត ។

ធានី ៖ ហើយកាលហ្នឹងពូរាយការណ៍អ្នកណាគេ?

ធឿយ ៖ ឈ្មោះភ្លីននេះឯង ។

ធានី ៖ ភ្លីន?

ធឿយ ៖ បាទ! គេកម្មាភិបាល ។

ធានី ៖ ភ្លីនហ្នឹង យើងរាយការណ៍ប្រាប់គេទៅ?

ធឿយ ៖ បាទ!

ធានី ៖ ហើយដល់ពេលចាប់គាត់បានទេ?

ធឿយ ៖ គាត់រត់ផុត ។

ធានី ៖ រត់ផុតដល់ថៃហើយ?

ធឿយ ៖ បាទ! ដល់ថៃ ។

ធានី ៖ គាត់នៅរស់ទេ?

ធឿយ ៖ នៅរស់សព្វថ្ងៃ នៅធ្វើអាចារ្យវត្តបន្ទាយឆ្មារ ។

ធានី ៖ ចុះពូដែលថាជីតាហ្នឹង គាត់រត់មកវិញ គាត់ស្លាប់នៅឆ្នាំណា?

ធឿយ ៖ គាត់ស្លាប់បាន៣ឆ្នាំ ប្រហែល២០០៧ ។

ធានី ៖ ២០០៧ ៣ឆ្នាំ ។ ចឹងពូដល់៧៨ ត្រឡប់មកភូមិវិញ ធ្វើស្រែ ធ្វើអីដែលថាមានសារពូបិទភ្លឺស្រែបិទអីហ្នឹង រហូតដល់វៀតណាមចូលមកបុកយ៉ាងម៉េច?

ធឿយ ៖ បាទ! រហូតដល់វៀតណាមចូលមក ។

ធានី ៖ ចឹងពូអត់បានរត់ទៅណាជាមួយ?

ធឿយ ៖ រហូតដល់វៀតណាមចាប់ផ្ដើមចូល ពួកខ្ញុំប៉ុន្មាននាក់តាមសម្លាប់ខ្មែរក្រហម បាទ! នេះនិយាយពីប្រវត្តិខ្ញុំ ។

ធានី ៖ ពូ តាមសម្លាប់ខ្មែរក្រហម?

ធឿយ ៖ បាទ!

ធានី ៖ ម៉េចចឹងពូ?

ធឿយ ៖ ព្រោះតាមសងសឹក ។

ធានី ៖ អូ! ពូហើយនឹងអ្នកណាគេខ្លះដែលតាមសម្លាប់ខ្មែរក្រហម?

ធឿយ ៖ បាទ! ឲ្យគ្នីគ្នាខ្ញុំដែលនេះ វាមានច្រើនដែលបក្សពួកខ្ញុំដែលនេះមុនដំបូងតែ៣នាក់ទេ ។

ធានី ៖ អ្នកណាគេខ្លះ?

ធឿយ ៖ ឈ្មោះខ្ញុំមួយ ហើយអាឈ្មោះរាម យួនមួយ ឈ្មោះណាក់ អាល់នេះមួយ ។

ធានី ៖ ណាក់អាល់?

ធឿយ ៖ បាទ! នេះនិយាយពីប្រវត្តិត្រឡប់ចុះត្រឡប់ឡើង ។

ធានី ៖ ណាក់អាល់ហ្នឹង ៣នាក់ហ្នឹង គាត់៣នាក់ហ្នឹង គឺជាអ្នកផ្ដើមគំនិតក្នុងការសម្លាប់ខ្មែរក្រហមហ្នឹង?

ធឿយ ៖ បាទ! ហើយផ្ដើមគំនិតឈ្មោះអ្នកនេះទេ អ្នកផ្ដើមគំនិត ឈ្មោះអឺ!នែកតា បៀង និង មាខ្ញុំឈ្មោះ ថិត ។

ធានី ៖ តាបៀង?

ធឿយ ៖ បាទ! ឈ្មោះ បៀង ក្លាយបៀង ។

ធានី ៖ ក្លាយ បៀង?

ធឿយ ៖ បាទ!

ធានី ៖ គាត់នៅរស់ទេ?

ធឿយ ៖ ស្លាប់ហើយ ។

ធានី ៖ ក្លាយបៀត ហើយនឹងអ្នកណាគេ?

ធឿយ ៖ តាថិត ។

ធានី ៖ ថិត?

ធឿយ ៖ បាទ!

ធានី ៖ ផ្ដើមសម្លាប់ខ្មែរក្រហមហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ ផ្ដើម ហើយពួអ្នកដេញសម្លាប់?

ធឿយ ៖ បាទ! នេះហើយគប់គ្រាប់បែក ដល់ពេលវាបែកបាក់ ពួកខ្ញុំនេះ អានេះអាដៃជើងនេះអ្នកតាម ៗ ដល់តាមទៅបែកការណ៍ ដល់បែកការណ៍មិនដឹងធ្វើម៉េចរត់ទៅថៃ ៗ

ធានី ៖ ពូ?

ធឿយ ៖ បាទ!ខ្ញុំរត់ទៅថៃ ៗ

ធានី ៖ ម៉េចចឹងពូ ក្រែងពួតាមសម្លាប់ខ្មែរក្រហម ម៉េចទៅខ្លាចបែកការណ៍?

ធឿយ ៖ ចុះវាបែកការណ៍ យើងនៅអត់បាន យើងអត់មានអាវុធ ៗ

ធានី ៖ អូ! ខ្មែរក្រហមដេញសម្លាប់វិញ?

ធឿយ ៖ បាទ! វាបែកការណ៍ ៗ

ធានី ៖ ចឹងកាលពេលដែលនេចុងក្រោយគេជាមួយវៀតណាមហ្នឹង តើអ្នកណាគេអ្នកគ្រប់គ្រងនៅហ្នឹង តាសារុំននឹងដដែល ឬក៏ដូរហើយ?

ធឿយ ៖ ដូរអស់ហើយ ៗ

ធានី ៖ ដូរ កាលហ្នឹងដូរទៅជាអ្នកណាវិញ បន្ទាប់ពីតាសារុំហ្នឹង?

ធឿយ ៖ តាសារុំ តាខ្ញុំភ្លេចឈ្មោះបាត់អស់ហើយចុងក្រោយ ពួកនិរតីពួកក្រោយ ឈ្មោះដល់វាមានគ្នាច្រើន បានឆាប់ជួយនឹកច្រើន ឈ្មោះនៅចុងប្រមុះឈ្មោះហ្នឹង ៗ នៅចាំខ្លះ អាប្រធានមិនបានចាំទេ ចាំតែពួកប៉ុសុង ពួកចាំអីនេះ ៗ

ធានី ៖ សុងហ្នឹងអ្នកណាគេ?

ធឿយ ៖ សុង ពួកនិរតី ៗ

ធានី ៖ សុងហ្នឹង គាត់ងាររជាអី?

ធឿយ ៖ ងាររខាងសន្ដាត់នេះ ពួកក្រោយ ៗ

ធានី ៖ សុងហ្នឹង?

ធឿយ ៖ បាទ! ព្រោះអត់មានប្រធានទេ អីឈ្មោះ៣០ឆ្នាំជាងហើយវាពិបាកគិតរក ៗ វាមានចៅសន្ដាត់៣ណាក់ បានត្រឹមតែចុះរក ៗ

ធានី ៖ ដំបូងមានសុង អ្នកណាគេមេទៅ?

ធឿយ ៖ សុង ភ្លេចបាត់ហើយ ដល់ប្រញាប់ប្រញាចេះ វាពិបាកគិត ៗ

ធានី ៖ អត់ទេ ពូគិតតាមសម្រួល ៗ

ធឿយ ៖ ក្មេងឈ្មោះគាត់បាត់ៗ មកដល់គិតឃើញភ្លាម ។

ធានី ៖ ចឹងពូអ្នកនិរតីមកៗតែ៣នាក់ ក្រៅពីហ្នឹងអត់មកអ្នកណាគេមកទេ អ្នកនិរតីដែលមកហ្នឹង?

ធឿយ ៖ មានប៉ុន្មាននាក់ អាម៉ាក់មួយ អាម៉ាក់នេះអត់មានប្រធានទេ អានេះកំពូលអ្នកសម្លាប់ បាទ! មានអាម៉ាក់ នេះអ្នកសម្លាប់ ។

ធានី ៖ សម្លាប់កន្លែងណាខ្លះទៅពូ?

ធឿយ ៖ អូ! បន្ទាយឆ្មារមិនសម្លាប់អស់តិចទេ អាម៉ាក់នេះ ។

ធានី ៖ ហេតុអីបានគាត់សម្លាប់ចឹង?

ធឿយ ៖ ទេ! មិនដឹងម៉េច អានេះវាសម្លាប់ៗតាំងពីពួកអតីតមុន តាំងពីពួកតាសារុំ ពួកអាអ្នកដែលធ្វើការមុនក៏វាសម្លាប់ដែរ ។

ធានី ៖ អូ! អតីតខ្មែរក្រហម ក៏សម្លាប់ដែរ?

ធឿយ ៖ បាទ! នោះហើយ ។

ធានី ៖ ហើយអ្នកណាទៀត ពូ?

ធឿយ ៖ អានេះអាម៉ាក់ អត់មានប្រធានទេ នៅមួយទៀតប្រធានក្មេងឈ្មោះ មិនចេះតែនៅៗបាននឹក ឃើញ ។ ក្មេងឈ្មោះអីត្រង់ណា មានមួយទៀត តាមួយនោះអាចារ្យ ប៉ុន្តែតានោះក៏ក្មេង ឈ្មោះដែរ ។ ឈ្មោះ បើយើងមានគ្នា២-៣នាក់អី យើងស្រួលនឹកៗឃើញលឿន ម្នាក់ឯង ដល់យើងសួរវា ។

ធានី ៖ គិតតែម្នាក់?

ធឿយ ៖ បាទ! ត្រឡប់ចុះត្រឡប់ឡើងទៅ ។

ធានី ៖ ម្នាក់ឯងដែរ?

ធឿយ ៖ បាទ! វាក្មេងឈ្មោះ ។

ធានី ៖ តែមិនអីទេ អត់ចាំក៏អត់អីដែរ ចឹងបន្ទាប់មកទៀត ពេលហ្នឹងពូតាមសម្លាប់ពួកគាត់ ឬក៏តាមសម្លាប់ អ្នកណាផ្សេង?

ធឿយ ៖ តាមសម្លាប់ពួកនេះៗដែលតាម អានេះគឺជាសំណាងល្អរបស់ខ្ញុំដែរ ដល់ពេលវាតាមៗវាធ្លាប់ស្គាល់ខ្ញុំ ដល់តាមៗជួបខ្ញុំ ដល់វាជួប វាអត់ដឹងថាខ្ញុំតាមទេ ហើយខ្ញុំវានាំគ្នាដើរដុំទៀត ។ នេះអាម៉ាក់ ដែលឈ្មោះ ម៉ាក់នេះ ។ បាទ!នាំខ្ញុំដើរដុំ ។

ធានី ៖ ដើរដុំម៉េចពូ?

ធឿយ ៖ ដើរដុំវា ប៉ុន្តែវាមានកាំភ្លើង ។

ធានី :   ចាំ! ហើយម៉េចទៀតទៅពូ?

ធឿយ : ប៉ុន្តែដែលដើរជុំទៅខ្ញុំអត់ទុកចិត្តក៏គេចខ្លួន ។

ធានី :   អូ! ពូរត់គេចខ្លួន?

ធឿយ : បាទ! ខ្ញុំខ្លាចវែបែករឿងវែបែកអី ខ្លាចវាដឹងទៅវាសម្លាប់ចោល ។

ធានី :   ចឹងទៅក៏ពូទៅ?

ធឿយ : ខ្ញុំគេចខ្លួនទៅខ្ញុំទៅថៃ ។

ធានី :   ទៅថៃដែរ ទៅតែម្នាក់ឯងទេ?

ធឿយ : ខ្ញុំទៅ ។

ធានី :   ចុះគ្រួសារអី?

ធឿយ : អត់ទៅទេ រត់ទៅនឹងហើយ ។

ធានី :   អូ! គាត់នៅនេះ ពូអ្នករត់ទៅនោះ?

ធឿយ : គេជម្លៀសនេះអស់ ខ្មែរក្រហម ។

ធានី :   ជម្លៀសទៅណា?

ធឿយ : ជម្លៀសទៅត្បូង ជម្លៀសទៅម្ខាក់ ។

ធានី :   ជម្លៀសប្រជាជនចេញទៅ?

ធឿយ : បាទ! អត់មាននៅសល់ទេ ជម្លៀសចេញអស់ ។

ធានី :   ជម្លៀសចេញទៅចឹងធ្វើអី?

ធឿយ : វាជម្លៀសទៅគោលបំណងវា វាជម្លៀសយកទៅសម្លាប់ចោល ។ វាខ្មែរវាអីច្រើនដាច់សម្លាប់ចោលទៅ ដល់ខ្ញុំរត់ចេញទៅ ខ្ញុំអឺ!ទៅទាក់ទងជាមួយប៉ារ៉ា ៗ ដែលឈ្មោះ ឆេង ធឿន នោះឯង ដែលខ្ញុំនិយាយកម្មាភិបាល គាត់គេចទៅមុន គាត់ទៅធ្វើប៉ារ៉ា ។ អតីតគាត់ខ្មែរក្រហមដែរ ដល់នេះរត់ជួបគ្នាទៅបានសហការគ្នាមក ។

ធានី :   ចឹងពូធ្វើប៉ារ៉ាដែរ?

ធឿយ : ខ្ញុំធ្វើអត់យូរទេ ។

ធានី :   ពូធ្វើបានប៉ុន្មានខែដែរ?

ធឿយ : ខ្ញុំធ្វើប្រហែលជា៤ខែ ៥ខែនោះឯង ព្រោះខ្ញុំធ្វើទៅវាអត់បានសម្រេច ។

ធានី :   ម៉េចចឹងពូ?

ធឿយ ៖ ព្រោះវាអត់បានសម្រេច ពេលណាដែរ ខ្ញុំថាជាគំនិតមកយើងថាទៅសងសឹកណា៎ ដល់ពេលយើងត្រឡប់ទៅថៃ ហើយមេទ័ពធំៗនៅថៃខ្មែរនៅថៃស្រែកថា សត្រូវលេខ១គឺយួនៗ គេត្រឡប់បេះ បាទ!ខ្ញុំអស់សង្ឃឹមៗ

ធានី ៖ ចឹងពូឈប់ធ្វើទៅ?

ធឿយ ៖ បាទ! ខ្ញុំក៏ចុះមកនៅខ្មែរវិញ បាទ!បេះត្រឡប់ចុះត្រឡប់ឡើងៗ

ធានី ៖ ចឹងកាលពេលពូរត់ទៅថៃឆ្នាំប៉ុន្មាន?

ធឿយ ៖ ខ្ញុំអឺ!៧៨ៗ

ធានី ៖ ចុង៧៨?

ធឿយ ៖ បាទ! ចុង៧៨ៗ

ធានី ៖ ចុង៧៨ បានជួបទាហានប៉ាវ៉ាបាន៤-៥ខែ ត្រឡប់មកភូមិវិញ?

ធឿយ ៖ បាទ! បាន៤ខែៗ

ធានី ៖ ពេលពូមកភូមិវិញឆ្នាំប៉ុន្មាន?

ធឿយ ៖ នៅ៧៩ៗ

ធានី ៖ ៧៩ពេលហ្នឹងកងទ័ពវៀតណាមចូលដល់ភូមិយើងឥឡូវ?

ធឿយ ៖ ចូល ថាមកសារភាពយួននេះឯងៗ

ធានី ៖ ចូលក្នុងភូមិ?

ធឿយ ៖ បាទ! វាខុសគោលបំណងៗ

ធានី ៖ ហើយពូថាពូមកសារភាពទៀត ពូអត់មានធ្វើអីផង ពូប្រជាជន?

ធឿយ ៖ ព្រោះៗខ្ញុំប៉ាវ៉ានោះ ត្រូវមកសារភាពយួន ចុះយួនចាប់ដាក់គុកទៀតៗ

ធានី ៖ ដោយសារឃើញពូពាក់ខោអាវប៉ាវ៉ា?

ធឿយ ៖ អត់ទេ យើងដូរៗចេញៗ

ធានី ៖ ដូរក៏ដោយក៏យើងប្រាប់គេថា យើងធ្វើប៉ាវ៉ាដែរ?

ធឿយ ៖ បាទ! តែយើងចេញ ហើយយើងចូលមកវិញហើយ គឺយើងប៉ាវ៉ាហើយ ត្រូវសារភាពៗ

ធានី ៖ ឲ្យតែយើងចេញពីភូមិ ទោះយើងជាប្រជាជនក៏ដោយក៏គេអត់ចាត់ទុកយើងជាប្រជាជនដែរ យើងត្រូវសារភាព?

ធឿយ ៖ អត់ទេ បើសិនជាប្រជាពលរដ្ឋដែលយើងរត់នៅតាមភូមិអត់អីទេ តែបើយើងបានរត់ត្រឡប់ទៅថៃហើយ ត្រូវតែសារភាពវាហើយ បាទ!គេហៅយើងទៅរៀនសូត្រ ទៅណែនាំយើងៗ

ធានី ៖ ចឹងកាលពេលពូធ្វើប៉ាវ៉ាហ្នឹង គេមានហ៊ឹកហាត់ពូដែរអត់?

ធឿយ ៖ ហាត់ដែរ ។

ធានី ៖ ហាត់ប៉ុន្មានខែ?

ធឿយ ៖ ខ្ញុំហាត់ប្រហែលជា២ខែ ហាត់ ។ ដែលខុសគោលមំណាងដែល គេថាសត្រូវលេខ១គឺយួន អត់មានជាមួយខ្មែរក្រហមទេ វា ។

ធានី ៖ ចឹងដល់ពេលពូត្រឡប់មកភូមិវិញ មកពូធ្វើងារជាអីដែរ ពេលមកដល់ភូមិ ហើយពេលជួបវៀតណាមហ្នឹង អ្នកណាគេស្គាល់ជំនាញការវៀតណាម ស្គាល់ឈ្មោះគាត់ទេ ដែលមកសារភាពហ្នឹង?

ធឿយ ៖ ជំនាញការវៀយណាមឈ្មោះអីគេ ភ្លេចបាត់ហើយ ។

ធានី ៖ ដូចថាអ្នកណា អ្នកគ្រប់គ្រងនៅយើង?

ធឿយ ៖ មេឃុំ ។

ធានី ៖ មេឃុំ?

ធឿយ ៖ មេឃុំយើងឈ្មោះ តាដឿម ។

ធានី ៖ តាដឿម?

ធឿយ ៖ បាទ! មេឃុំដឿម ។

ធានី ៖ ដឿមៗជាមេឃុំ?

ធឿយ ៖ បាទ!

ធានី ៖ មេឃុំបន្ទាយឆ្មារហ្នឹងពូហេ៎?

ធឿយ ៖ បាទ! មេឃុំ ។

ធានី ៖ ហើយពូសារភាពជាមួយគាត់ហ្នឹង?

ធឿយ ៖ សារភាពជាមួយជំនាញការៗឈ្មោះ ប៊ិចាយ បាទ! ឈ្មោះ ចាយ ។

ធានី ៖ កងចាយ?

ធឿយ ៖ ចាយ វៀតណាម ។

ធានី ៖ ហើយមកសារភាពជាមួយចាយហ្នឹងហើយ ទៅបានដឿមហ្នឹងនាំធ្វើការធ្វើអី?

ធឿយ ៖ បាទ! គេឲ្យយើងនៅជាប្រជាពលរដ្ឋធម្មតាទៅ ។

ធានី ៖ ជួបមុខគ្រួសារជួបអី?

ធឿយ ៖ បាទ! ហើយដល់ពេលនេះ គេឲ្យយើងធ្វើការងារដូចជាគ្រូបង្រៀនអី ក៏ខ្ញុំអត់ធ្វើ ។

ធានី :   អូ! គេឲ្យពូធ្វើគ្រូបង្រៀនដែរ?

ធឿយ : បាទ! ឲ្យធ្វើគ្រូបង្រៀន។

ធានី :   ម៉េចបានអត់ធ្វើវិញ?

ធឿយ : ប៉ុន្តែ ព្រោះខ្ញុំនឹកឃើញពីប្រវត្តិឪពុកខ្ញុំទៅ។

ធានី :   អូ! ដោយសារប្រវត្តិឪពុកធ្វើជាការងាររដ្ឋអីចឹង?

ធឿយ : បាទ! គេសម្លាប់អីៗ ខ្ញុំខ្លាចសង្គមក្រោយៗប្រែប្រួលទៅ។

ធានី :   ខ្លាចសម្លាប់ទៀត?

ធឿយ : បាទ! ហើយដល់ក្រោយមកក៏គេទាក់ទងឲ្យខ្ញុំចូលធ្វើការខាងឃុំទៀត ក៏ខ្ញុំអត់ធ្វើ ខ្ញុំចេះតែគេរហូត។

ធានី :   បង្រៀប បន្ទាប់មកទៀត ធ្វើការខាងឃុំ?

ធឿយ : បាទ!

ធានី :   ក្នុងឃុំហ្នឹងធ្វើជាអីកាលហ្នឹងធ្វើជាអី?

ធឿយ : ក្រុមប្រឹក្សាឃុំ វាមិនមែនក្រុមប្រឹក្សាឃុំទេ យើងមានកាលពីដើមមិញយើងមានមេឃុំ ជំទុកលេខ១ ជំទុកលេខ២។

ធានី :   ជំទុកលេខ១ លេខ២ ស្មៀន?

ធឿយ : ហើយវា បាទ!វាមានស្មៀន។ បាទ!ហើយកាលដែលឲ្យធ្វើនេះគ្រាន់ធ្វើស្មៀនទេ គេប្រុងដូរប៉ុន្តែខ្ញុំអត់ព្រម។

ធានី :   អត់ធ្វើ ហើយពូធ្វើអីវិញទៅ?

ធឿយ : ខ្ញុំៗនៅធ្វើស្រែធម្មតា ខ្ញុំអត់។

ធានី :   ធ្វើស្រែដូចរាល់ថ្ងៃហ្នឹង?

ធឿយ : បាទ!

ធានី :   ចុះមុនហ្នឹងពូនិយាយថាទិដ្ឋភាពវៀតណាមវៃអីចឹងនោះ អាចពូជួយប្រាប់បានទេ ពេលពូមកដល់ភូមិអាចពូជួយប្រាប់តិចបានទេ   ពេលពូមកដល់ភូមិវិញ   ដូចថាតើវាមានចំរូងចំរះអីរវាងប៉ុល្ពតខ្មែរក្រហម ជាមួយវៀតណាម ទៅមកៗក្នុងភូមិយើងនេះ?

ធឿយ : ទេ! អារឿងការដែលយើង ការវៃគ្នានៅភូមិនេះជាតំបន់សង្គ្រាមក្តៅគក់ហើយកន្លែងនេះណាវាមានយើងវាមានអា វាមាន៣ភាគី ដល់វាមានខ្មែរក្រហម វាមាន៤នោះ វាមានប៉ុល្ពតសឹង

សាន ប៉ាំភាខាងសម្តេច ហើយយើងខាងកងពល វាត្រូវមាន៤ ហើយវៀតណាមទៀត ។ ភូមិនេះត្រូវប្រឈមមុខ ហើយភូមិនេះគឺសម័យនោះក្លាយជាផេះអស់ៗ ។

ធានី ៖ ភូមិអត់មានភូមិ?

ធឿយ ៖ បាទ! ក្លាយជាផេះអស់ ឆេះអស់គ្មានសល់ទេ សល់តែបាតដីទទេរ ។

ធានី ៖ ឆ្នាំប៉ុន្មានពូ?

ធឿយ ៖ អឺ! នៅឆ្នាំ១៩៨៣ ។

ធានី ៖ ៨៣ក្លាយជាផេះ?

ធឿយ ៖ ៨២ ៨៣អាហ្នឹងក្លាយជាផេះអស់ហើយ អត់មានសល់អីទេ ។

ធានី ៖ អត់មានសង្គ្រាម ហើយចឹងទៀតពូ ហើយចឹងប្រជាជនទៅនៅណាទៅ?

ធឿយ ៖ ប្រជាពលរដ្ឋគេជម្លៀសទៅនៅសាម៉ន់ ខាងជើងស្រុកស្វាយចេក ។

ធានី ៖ ភូមិម្នាក់ហ្នឹងមែន?

ធឿយ ៖ អត់ទេ អាយើងស្រុកស្វាយចេកយើង ខាងត្បូងថ្មពួក ស្រុកថ្មពួក ។

ធានី ៖ គេហៅភូមិឃុំអី?

ធឿយ ៖ គេហៅសាម៉ន់ ហើយម៉ាចំនួនរត់ចូលព្រៃ គេបែងចែក ។

ធានី ៖ ម៉េចទៀតទៅពូ?

ធឿយ ៖ បាទ! អានេះយើងនិយាយដែលបែកបាក់ ។

ធានី ៖ ចុះការហូបចុក ការអី ការរស់នៅយ៉ាងម៉េច?

ធឿយ ៖ ការរស់នៅ គឺអ្នកភូមិនេះវេទនាបំផុត ដោយសារយើងរស់នៅជ្រៀតជ្រែកនៅភូមិគេទៅ យើងខ្វះដីធ្លីអីទៅវាពិបាក ។ ដល់ហើយក្នុងគ្រួសារម្នាក់ៗ គឺសម្រេចចិត្តរត់ទៅព្រំដែន ។ បាទ! ភាគច្រើនគឺរត់ទៅព្រំដែន ។

ធានី ៖ ពូបានទៅហ្នឹងគេទេ?

ធឿយ ៖ ខ្ញុំអត់បានទៅទេ ខ្ញុំទៅថាខ្ញុំទៅក្រោយគេក៏ថាបាន ខ្ញុំទៅអឺ!ខ្ញុំទៅបាន២ឆ្នាំ ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ធឿយ ៖ ខ្ញុំទៅអឺ! នៅឆ្នាំអា១៩៨០ ។

ធានី ៖ ១៩៨០?

ធឿយ ៖ ៨៨ ។

ធានី ៖ ៨៨ ៨៩ចឹង?

ធឿយ ៖ បាទ!

ធានី ៖ ៨៩ទៅប្រទេសថៃៗ?

ធឿយ ៖ ទៅៗជំរំ។

ធានី ៖ ទៅជំរំហ្នឹងជំរំអីគេ?

ធឿយ ៖ ទៅជំរំសាយធូ។

ធានី ៖ ជំរំសាយធូ?

ធឿយ ៖ បាទ!

ធានី ៖ សាយធូប្រទេសថៃពូ?

ធឿយ ៖ បាទ!

ធានី ៖ ហើយពូទៅនៅជំរំបាន២ឆ្នាំ ទៅនៅហ្នឹងរស់នៅយ៉ាងម៉េចដែរ សាយធូរ?

ធឿយ ៖ បាទ! ព្រោះដែលខ្ញុំរត់ទៅរស់នៅនេះ ខ្ញុំអត់មានទៅធ្វើតាហាន ទៅអីទេ ទៅនៅរៀន។

ធានី ៖ រៀនអីគេ?

ធឿយ ៖ បាទ! ខ្ញុំរៀនទាំងអក្សរ រៀនទាំងតិចណិច រៀនទាំងអស់។

ធានី ៖ តិចណិចម៉េចពូ?

ធឿយ ៖ ខាងគ្រឿងម៉ាស៊ីន គ្រឿងអី។

ធានី ៖ គ្រឿងម៉ាស៊ីនអីគេទៅ?

ធឿយ ៖ គ្រឿងម៉ាស៊ីនម៉ូតូអាគុយ អឺ!ម៉ាស៊ីនគោយន្ត ម៉ាស៊ីនឡានអី។

ធានី ៖ មានគេបង្រៀនដែរ?

ធឿយ ៖ បង្រៀន ខាងដុនបូស្កូល។

ធានី ៖ អឺ! ដុនបូស្កូលហ្នឹងគេបង្រៀនតាមព្រំដែនហ្នឹងឯង បង្រៀនពីរបៀបដួសដុលអីចឹង?

ធឿយ ៖ បាទ! នៅដុនបូស្កូល កន្លែងជនពិការ។

ធានី ៖ ចឹងដុនបូស្កូលហ្នឹងមានយូរហើយ?

ធឿយ ៖ មានយូរហើយ។

ធានី ៖ ខាងបរទេស?

ធឿយ ៖ បាទ!

ធានី ៖ បរទេសអ្នកបង្រៀន?

ធឿយ ៖ បាទ!

ធានី ៖ ជនពិការ?

ធឿយ ៖ ជនពិការវាផ្សេង ដុនបូស្កូលផ្សេង ។

ធានី ៖ អឺ! ដុនបូស្កូលសម្រាប់រៀន?

ធឿយ ៖ បាទ! ហើយជនពិការក៏បច្ចេកទេសដូចគ្នា ។

ធានី ៖ ប៉ុន្តែរៀនជាមួយពូដែរអត់?

ធឿយ ៖ ព្រោះខ្ញុំៗរៀនអឺ!ដុនបូស្កូលក៏ខ្ញុំរៀន អាជនពិការក៏ខ្ញុំរៀន ប៉ុន្តែដល់មកខាងជនពិការ ខ្ញុំនៅជាគ្រូបង្រៀនខាងតិចណិចវិញ ។

ធានី ៖ អឺ! ចឹងពូនៅធ្វើគ្រូបង្រៀន ៨៨ ៨៩ក៏ពូនៅធ្វើគ្រូបង្រៀនដែរ គ្រូបង្រៀនបច្ចេកទេស?

ធឿយ ៖ បាទ! បច្ចេកទេស ។

ធានី ៖ ខាងកាលហ្នឹងជំនាញខាងអីគេ ពូ?

ធឿយ ៖ ខាងគ្រឿងម៉ាស៊ីន ។

ធានី ៖ ឲ្យតែគ្រឿងម៉ាស៊ីនអីក៏ដោយ ឡាន គោយន្ត ម៉ូតូ?

ធឿយ ៖ បាទ! ម៉ាស៊ីនឡាន បាទៗនៅបង្រៀនគេ ។

ធានី ៖ ព្រោះសម័យឥឡូវគេមានឡានៗទៅ ម៉ូតូៗទៅគេអត់លាយគ្នាចឹង ។

ធឿយ ៖ បាទ!

ធានី ៖ ចឹង៨៨ ៨៩ពូនៅថៃ ឆ្នាំ៨៩ពូត្រឡប់មកវិញ?

ធឿយ ៖ អឺ! ៩១ ។

ធានី ៖ ចឹង១៩៩១ ពូត្រឡប់មកវិញ ។ ចឹងពូនៅតាំងពី៨៨?

ធឿយ ៖ ទេ! ៨៩ខ្ញុំប្រឡំ មិនមែន៨៨ទេ ។

ធានី ៖ ៨៩ពូទៅថៃ ដល់ពេល៩១បានពូត្រឡប់មកវិញ?

ធឿយ ៖ បាទ!ត្រឡប់មកវិញ ។

ធានី ៖ ពេលហ្នឹងគេលែងមានជំរំហ្នឹង?

ធឿយ ៖ បាទ! គេរំសាយជំរំគេដឹកចូលវិញ ។

ធានី ៖ ចឹងពូត្រឡប់មកភូមិយើងវិញ?

ធឿយ ៖ បាទ!

ធានី ៖ មកភូមិយើងមានដី មានអីសម្រាប់រស់នៅដែរ?

ធឿយ ៖ បាទ! ដល់មកភូមិយើងខាងនេះ វាមានតំបន់យើងខាងនេះគេអត់ប្រកាន់ដូចទៅខាងក្នុងទេ ដីអ្នកណាយើងនោះនៅចឹង ។

ធានី ៖ របស់អ្នកណារបស់អ្នកហ្នឹងចឹង?

ធឿយ ៖ បាទ! ដីខ្ញុំចឹង ។

ធានី ៖ មិនចាំបាច់ចាប់យករបស់គេទេ?

ធឿយ ៖ បាទ!

ធានី ៖ ចឹងរបស់ពូនៅរបស់ពូដដែរ?

ធឿយ ៖ បាទ! នៅដដែល អត់មានអ្នកណាយកទេ ដីស្រែដូចជាអ្នកនៅចាស់គេមិនបានរត់ទៅ គេធ្វើចឹង ខ្ញុំត្រឡប់មកវិញគេប្រគល់ឲ្យវិញ ។

ធានី ៖ គេដឹងរបស់យើង?

ធឿយ ៖ បាទ!

ធានី ៖ ចឹងអ្នកនៅចាស់ហ្នឹង គេដឹងថាអាហ្នឹងរបស់យើងដែរ?

ធឿយ ៖ បាទ! នោះហើយ ។

ធានី ៖ អត់មានអ្នកនៅថ្មីមកយកដីវិញ អត់មាន?

ធឿយ ៖ អត់ទេ ។

ធានី ៖ អ្នកនៅភូមិយើងចឹងទាំងអស់?

ធឿយ ៖ បាទ! ទោះបីអ្នកមកថ្មី ធ្វើស្រែធ្វើដីយើង ក៏យើងមកវិញក៏ឲ្យគេ ។

ធានី ៖ គេប្រគល់ឲ្យវិញ គេទៅណាទៅ?

ធឿយ ៖ គេរកទៀត គេរកទិញទៀត ។

ធានី ៖ គេរកទិញម្តង?

ធឿយ ៖ បាទ! វាស្រួលចេះ ។

ធានី ៖ ចឹងយើងអត់មានបានប្រគល់ឲ្យគេ គ្រាន់តែគេជួយមើលដីស្រែឲ្យយើង?

ធឿយ ៖ បាទ!

ធានី ៖ ហើយយ៉ាងម៉េចទៀតទៅការរស់នៅតាំងពី៩១មក ធ្វើស្រែចំការរហូត?

ធឿយ ៖ បាទ! យើងធ្វើស្រែចំការរហូតមក ។

ធានី ៖ រហូតមកដល់ អឺ!បែករហូតមកដល់សព្វថ្ងៃ?

ធឿយ ៖ បាទ! រហូតមកដល់សព្វថ្ងៃ ។

ធានី ៖ ដូចថាចំពោះចិត្តពូផ្ទាល់ ពូយល់ថាចំពោះការរស់កាលពីមុនរហូតមកដល់សម័យឥឡូវ តើពូយល់ថាសម័យ ចិត្តពូៗយល់ថាយ៉ាងម៉េចចំពោះសម័យមុន?

ធឿយ ៖ចេះ បើសម័យបើតាមដែលខ្ញុំធ្លាប់ឆ្លងកាត់ ខ្ញុំបានឆ្លងកាត់ច្រើនសង្គម តែយើងគិតនៅតាមក្នុងសង្គមដូចសង្គមលន់ នល់ ប៉ុន្តែយើងថាសប្បាយមែន ប៉ុន្តែវាពាក់ព័ន្ធជាមួយសង្រ្គាមជាមួយអាមេរិចៗ ពេលក្រោយមកទៀតទៅ ដល់សម័យខ្មែរក្រហមក៏វាយ៉ាប់ ដល់សម័យយើងវាធូរធា យើងរស់នៅស្រួលទៅ វាខុសប្លែកគ្នាឆ្ងាយ ។

ធានី ៖ ប្លែកគ្នាឆ្ងាយ?

ធឿយ ៖ បាទ! ឆ្ងាយណាស់ ។

ធានី ៖ ចឹងពូចាប់ផ្តើមធ្វើជាប្រធានភូមិពេលណាវិញ?

ធឿយ ៖ខ្ញុំមកធ្វើនៅឆ្នាំ២០០៣ ។

ធានី ៖ ម៉េចបានៗធ្វើប្រធានភូមិ?

ធឿយ ៖ព្រោះដែលខ្ញុំធ្វើទៅ ២០០៣នេះ ដោយសារប្រជាពលរដ្ឋភូមិនេះ គេស្រឡាញ់គេរាប់អានហើយជាពិសេសចាស់ៗ ។ ខ្ញុំអត់ធ្វើទេខ្ញុំប្រកែកដាច់អហង្ការការពិតថាខ្ញុំមិនធ្វើ ។ បាទ!ប៉ុន្តែដល់យើងចាស់ៗគាត់ច្រើន គាត់គិតឃើញថា ពីប្រវត្តិឪពុកខ្ញុំគាត់ធ្វើការមិនដែលមានថាល្អក់កកជាមួយប្រជាពលរដ្ឋណា ។ ដល់ចុះគាត់ចង់បាន គាត់ចេះតែមេភូមិមុនៗគេដកចេញអស់ ទៅក៏គេឲ្យខ្ញុំធ្វើចេះឯង ។

ធានី ៖ ដោយសារតែមើលឃើញពីប្រវត្តិតាំងពីអើយអាយមក?

ធឿយ ៖ បាទ! ហ្នឹង អានេះខ្ញុំនិយាយការពិតចឹង ។

ធានី ៖ ហើយចឹងពូធ្វើមេភូមិនៅភូមិបន្ទាយឆ្មារខាងជើងចឹង?

ធឿយ ៖ បាទ!

ធានី ៖ ចឹងពូដឹងថារបៀបកកើត របៀបថាភូមិឃុំតាំងពីពេលណាមកទេ?

ធឿយ ៖ឃុំអី!ឃុំនេះ

ធានី ៖ ភូមិឃុំយើង?

ធឿយ ៖ភូមិឃុំនេះកកើតប្រហែលពី បើនិយាយពីប្រវត្តិសាស្រ្តខ្ញុំបានតែងតើប៉ុន្តែខាងស៊ីម៉ាក់គេយក ទៅ ។ បានខ្ញុំតែងពីប្រវត្តិ ។

ធានី ៖ ចុះពូមាននៅសល់ទៀតទេ?

ធឿយ ៖ អត់មាននៅសល់ទេ គេយកទៅធ្វើជាសៀវភៅឲ្យខ្ញុំ ។បើប្រវត្តិភូមិនេះ ។

ធានី ៖ ចុះពូមានទេឥឡូវ?

ធឿយ ៖ គេអត់ទាន់បញ្ជូនវិញទេ គេធ្វើជាសៀវភៅឲ្យខ្ញុំ បើប្រវត្តិភូមិនេះបើសិនបានអានប្រហែលស្រក់ទឹកភ្នែកដែលខ្ញុំតែង ។ បាទ! ព្រោះខ្ញុំតែងអានឲ្យប្រជាពលរដ្ឋខ្លះស្រក់ទឹកភ្នែកនោះ ។

ធានី ៖ ពូអាចជួយនិយាយប្រាប់តិចបានទេ?

ធឿយ ៖ បាទ! ព្រោះភូមិកំណើតនេះ គេហៅជាកំណើតភូមិអ្នកទោស ។

ធានី ៖ ចឹងភូមិបន្ទាយឆ្មារហ្នឹង ហៅភូមិអ្នកទោសទេ?

ធឿយ ៖ បាទ!

ធានី ៖ ភូមិយើងនេះ ឬក៏ឲ្យតែបន្ទាយឆ្មារ?

ធឿយ ៖ នេះឯង ៗ អ្នកកំណើតបន្ទាយឆ្មារនេះ អ្នកកំណើតមុនដំបូង អ្នកដែលកកើតនឹងទឹកដីបន្ទាយឆ្មារ ។

ធានី ៖ ជាភូមិអ្នកទោសទេ?

ធឿយ ៖ បាទ! អ្នកទោសរាជការ គេហៅទោសសម័យនោះនៅក្នុងអាណានិគមន៍បារាំងបាទ!គេហៅអ្នកទោសរាជការ កាលនោះគេត្រូវឲ្យប្រជាពលរដ្ឋនោះ អឺ!អាបង់កាត៥ផ្នត់នោះ ហៅកាត់៥ផ្នត់ ក្នុងមួយគ្រួសារ៥រៀល ។ ប៉ុន្តែអ្នកដែលនៅបន្ទាយឆ្មារនេះ អត់មានអ្នកបន្ទាយឆ្មារទេ អតីតគឺអ្នកនៅថ្មពួកនៅអីនេះឯង ។ ប៉ុន្តែដល់ខាងរាជការម៉ាជិនាន់នោះ គេថាបើអ្នកណាហ៊ានមកនៅបន្ទាយឆ្មារគេលើកលែងទោសឲ្យ ។ ដល់ចឹងហើយពួកគាត់ក៏សម្រេចចិត្តចូលមករស់នៅបន្ទាយឆ្មារ ដូចព្រៃស្មួសានចឹងឯង ខ្លា ដំរី មក ។ ពេលដែលគាត់ចុះមកនៅនេះគាត់នៅខាងនេះប្រាសាទ នៅត្រង់នេះ ។

ធានី ៖ ខាងណាប្រាសាទ?

ធឿយ ៖ នៅខាងនោះខាងជើងប្រាសាទ ។ ពេលដែលគាត់នៅបានកកើតបានជាក្រុម គាត់មាន២ក្រុម ៗ មួយក្រុមចោរ ក្រុមមួយប្រជាពលរដ្ឋសុទ្ធសាធ ។ ដល់ពេលគាត់នៅរស់នៅទៅដោយសារសម័យនោះ ទឹកដីនេះវាខ្លាំង ស្លាប់ ។

ធានី ៖ ខ្លាំងយ៉ាងម៉េច?

ធឿយ ៖ គាត់ស្លាប់ចង់អស់ពូជ ។

ធានី ៖ ស្លាប់រឿងអី?

ធឿយ ៖ ស្លាប់នឹងជម្ងឺ ស្លាប់ទាំងអស់ ។

ធានី ៖ ហេតុអីបានឈឺ ៗ អីគេ?

ធឿយ ៖ អត់ដឹងផង ។

ធានី ៖ គ្រូនចាញ់ ឬក៏អី?

ធឿយ ៖ វាឈឺសន្ធំស្លាប់ៗអស់ច្រើន ពូជ ។

ធានី ៖ កន្លែងហ្នឹងព្រៃក្រាស់ពេកម៉េចពូ?

ធឿយ ៖ វាព្រៃក្រាស់ដូចជាវាព្រៃខ្លាំងដឹងស្លាប់ៗអត់បាន ស្លាប់ៗទៅ ហើយណាមួយថៃវាឈ្លានពាន ប្រហែលជានៅឆ្នាំ១៩៨០ជាង ៨១ ឬ៨២ ថៃវាចូលមកឈ្លានពានមក វាចូលមកវាក៏វាសម្លាប់ទៀត ។ ហើយក្នុងម៉ាថ្ងៃ ពុតែសម្ងេទ្រព្យគយរបស់ប្រជាពលរដ្ឋទេ ។ វាមិនដឹងជា វាជួយយកអ្នកណាទៅកប់ណា វាស្លាប់ច្រើនពេក ប្រវត្តិភូមិនេះវាវេទនា ។

ធានី ៖ ម៉េចទៀតពូ?

ធឿយ ៖ ក្រោយមកគាត់ក៏ចាកចេញពីទឹកដីនេះ គាត់ទៅនៅនោះ នៅខាងត្បូងបារាយណ៍បុណ្យយើងដល់នៅនោះថៃទៅសម្លាប់នោះទៀតៗ គាត់មិនដឹងធ្វើម៉េច គាត់សម្រេចមកនៅអាភូមិនេះទឹកដីនេះ ដែលបានក៏រស់នៅសព្វថ្ងៃ ។ ហើយគាត់ធ្វើស្រែធ្វើចំការគាត់ បើសិនជាគាត់ធ្វើទៅបានផលពាក់កណ្តាលអត់ពាក់កណ្តាល ដោយសារសត្វព្រៃ ។ ម៉ាថ្ងៃៗបើថាយើច្រូតស្រូវជាកណ្តប់ចេះអាសត្វស្វានេះជញ្ជូនយកអស់ ។

ធានី ៖ អឺៗ ជញ្ជូនម៉ាកណ្តប់ៗ?

ធឿយ ៖ បាទ! នេះក្នុងប្រាសាទបន្ទាយឆ្មារនេះ សុទ្ធតែខ្លាដំរី ស្វា ពេញណាពេញណែដបូរណាស់សុទ្ធតែ ប្រវត្តិចាស់ៗដែលគាត់ ។

ធានី ៖ ចឹងប្រាសាទហ្នឹងរបៀបថាគេមានតែប្រាសាទដូចថាកាលពីអើយ! អាយមកមានតែប្រាសាទតែមួយទេ ឬមួយក៏វាមានភូមិប្រជាជនរស់នៅមុនហើយគេបោះបង់វាចោល?

ធឿយ ៖ ព្រោះអឺ!ប្រាសាទនេះ តាំងពីដើមមកអត់មានអ្នកណានៅទេ គេនៅបោះបង់ចោល ។

ធានី ៖ បោះបង់ចោល?

ធឿយ ៖ បាទ!

ធានី ៖ ដីជុំវិញហ្នឹងអត់មានអ្នកណានៅ?

ធឿយ ៖ បាទ! អត់មានអ្នកណានៅទេ ។ ព្រោះខ្ញុំក៏មិនបានកើតទាន់ដែរ ខ្ញុំទាន់ ព្រោះខ្ញុំកើតនៅឆ្នាំ ១៩៥៣ ខ្ញុំកើតឆ្នាំឯករាជ្យ ។

ធានី ៖ ចា៎!ឯករាជ្យ សម័យសុខសាន្ត?

ធឿយ ៖ បាទ! សម័យសីហនុ បាទ! ព្រោះកាលដែលខ្ញុំកើតឪពុកខ្ញុំជាឥស្សរៈទេ ប្រវត្តិឪពុកខ្ញុំគឺគាត់រំដោះជាតិរហូត ។

ធានី ៖ ចឹងមុនហ្នឹងទៀត ឪពុកពូបាននិយាយរឿងរ៉ាវអស់ហ្នឹងប្រាប់ពូ ឬយ៉ាងម៉េច?

ធឿយ ៖ គាត់បាននិយាយ

ធានី ៖ ថារឿងប្រវត្តិកន្លែងអ្នកទោស កន្លែងអី?

ធឿយ ៖ អាហ្នឹងជីតាទេ ។

ធានី ៖ អូ! ជីតាប្រាប់?

ធឿយ ៖ បាទ! ជីតាៗគាត់និយាយៗប្រាប់ទៅ ព្រោះបើសិនយើងនិយាយ យើងតែងខ្ញុំតែងរហូតៗសព្វថ្ងៃ ព្រោះខាងស៊ីម៉ាក់គាត់ឃើញ គាត់ចង់បានគាត់យកទៅរៀបចំជាសៀវភៅឲ្យ ។

ធានី ៖ ចង់បានដែរ?

ធឿយ ៖ បាទ! ហ្នឹងហើយ ។

ធានី ៖ ចឹងដឹងម៉េចចង់មើល ចង់ដឹងពីប្រវត្តិភូមិយើង ព្រោះគេហៅភូមិអ្នកទោសអីណា?

ធឿយ ៖ បាទ! ព្រោះនែក!

ធានី ៖ ចឹងគេហៅភូមិហ្នឹងហៅភូមិអ្នកទោសចឹងកាលពីមុន?

ធឿយ ៖ ពីមុនភូមិ គេហៅភូមិទោស ប៉ុន្តែឈ្មោះអ្នកបន្ទាយឆ្មារ ដែលគេនិយាយ គេថាហៅភូមិអ្នកទោសដោយសារៗនែក!រាជការបញ្ជូនអ្នកទោសមក ។

ធានី ៖ អូ! មានអ្នកទោសមកហ្នឹងទៀត?

ធឿយ ៖ អាអ្នកទោសដូចខ្ញុំនិយាយមិញ អ្នក ។

ធានី ៖ ថាមានចោរមានអីហ្នឹង?

ធឿយ ៖ បាទ! អ្នកទោសកាត់៥ផ្នត់ បើយើងអត់មានបង់ សម័យនោះបារាំងជាមួយខ្មែរឃុបឃិតជាមួយគ្នាធ្វើបាបនោះចេះឯង ។

ធានី ៖ កាត់៥ផ្នត់ហ្នឹងយ៉ាងម៉េច ពូបង់ប៉ុន្មាន?

ធឿយ ៖ បង់៥រៀលៗសម័យនោះយើងរកអត់បានទេ ៥រៀលគោម៉ានឹម ហើយព្រោះគាត់ក្ររកអត់បាន ។

ធានី ៖ ចឹងគេបញ្ជូនមកហ្នឹងប៉ុន្មាននាក់ ពូចាំទេ?

ធឿយ ៖ ហើយគាត់មកនៅប្រមូលផ្តុំគ្នាបានប្រហែលជា៤០ទៅ៥០គ្រួសារ
ហើយម៉ាក្រុមនៅត្រង់នេះ ប្រហែលជា៤-១០គ្រួសារហ្នឹង ក្រុមចោរ

ដល់ហើយគេស្រណោះអាណិតទៅរាជការលើក លែងទោសឲ្យ ហៅអាក្រុមចោរហៅចោរៗហ្នឹង ឲ្យចូលខ្លួនមករាជញការគេទិញគោឲ្យម្នាក់ ម៉ានឹម ឲ្យចោរហ្នឹងឲ្យឈប់ធ្វើចោរ ។ ហើយក៏បានមករស់នៅជុំគ្នាជាមួយនេះទាំងអស់ ក៏ធ្វើគំនិតអាក្រក់ ។

ធានី ៖ ប៉ុន្តែពូថាស្លាប់មនុស្សច្រើនទេ នៅពេលហ្នឹងដែរអត់ទេ?

ធឿយ ៖ ពេលនោះដែរហ្នឹង ។

ធានី ៖ ដែលធ្វើរាជការទិញគោឲ្យក៏ដោយ ក៏នៅតែមានមនុស្សស្លាប់?

ធឿយ ៖ ស្លាប់ ដល់ក្រោយមកៗដែលមកនៅនេះបានមានឈប់ស្លាប់ ។

ធានី ៖ កាលហ្នឹងយើងមានអីការពារ បានឈប់ស្លាប់?

ធឿយ ៖ អត់មានទេ អត់មានថ្នាំសង្កូវ អត់មានការពារទេ ។

ធានី ៖ ចឹងកាលសម័យហ្នឹង ពូដែលឃើញ ព្រោះនៅបន្ទាយឆ្មារកន្លែងគេកប់សពអីកាលសម័យបូរាណ?

ធឿយ ៖ មិនខុះទេ នេះ ក្នុងម៉ាប្រទេសខ្មែរ គឺមានតែទឹកដីបន្ទាយឆ្មារនេះទេ ដែលកប់ផ្នូរបូរាណច្រើនជាងគេបង្អស់ ។

ធានី ៖ ហេតុអីពូ ហេតុអីបានជាកន្លែងហ្នឹងវិញ?

ធឿយ ៖ ព្រោះខ្ញុំអត់បានដឹងផង ព្រោះខ្ញុំបានសិក្សាជាមួយក្រសួងវប្បធម៌ដែរ ព្រោះខ្ញុំធ្លាប់និយាយជាមួយក្រសួងវប្បធម៌អីដួប គាត់ថា ខាងក្រសួងវប្បធម៌ក៏គាត់ឆ្ងល់ដែរ ហេតុអ៊ីបានមនុស្សស្លាប់នៅទឹកដីបន្ទាយឆ្មារច្រើន ។

ធានី ៖ ដូចថាគេយកមកកប់សពហ្នឹង វាវាលស្មោសាន អីចឹង?

ធឿយ ៖ បាទ! ហើយឲ្យតែមានគោ មិនបានទេ ខ្មោចម៉ាកន្លែង សឹងរាប់ម៉ឺនខ្មោច ។

ធានី ៖ ចឹងកាលពេលពូមក កាលជីតាពូនិយាយប្រាប់ចឹង កាលមកដល់ឃើញមានចឹងអត់?

ធឿយ ៖ អត់មានទេនោះៗ សម័យៗខ្មោចហ្នឹងគេរកឃើញក្រោយទេ ។

ធានី ៖ ចឹងកាលសម័យមុនក៏អត់ដឹងថាកន្លែងហ្នឹងមានទេ?

ធឿយ ៖ អត់ដឹងទេ គេថាយើងឃើញតែទួលខ្ពស់ គិតថាទួលភូមិហើយ ប៉ុន្តែអាទួលខ្ពស់នេះទួលខ្មោចទេ ។ ខ្មោចគេមានកប់៣ជាន់កប់ពីលើៗគ្នាចេះដេញ ហើយគេកប់ចេះតែលើកៗទួលឲ្យខ្ពស់នោះសុទ្ធតែទួលខ្មោចបូរាណហើយ ។

ធានី ៖ ខ្មោចបូរាណហ្នឹង សុទ្ធតែទួលអ្នកដូចថាអ្នកមានបុណ្យមានសក្តិ ឬមួយក៏ប្រជាជនធម្មតា?

ធឿយ ៖ វាមាន អ្នកដែលមានបុណ្យសក្តិ វាមានបើតាមខ្ញុំធ្លាប់សិក្សា ហើយពួកបូរាណវិទ្យាគាត់នាំខ្ញុំដើរមើលណា គាត់ឲ្យខ្ញុំជូនមើលទៅ វាសព្វថ្ងៃអត់ដឹកបានទេ សព្វថ្ងៃ ។

ធានី ៖ ម៉េចចឹង?

ធឿយ ៖ គាត់វិភាគមើលទៅ វាប៉ះពាល់ច្រើន ដល់យើងគាស់ផ្នូរបូរាណបំផ្លាញ់ចោលអស់ វាមានរបស់ថ្លៃៗច្រើន ក្នុងសាកសពមួយបើគេអ្នកៗដែលគេមានគ្រាន់ ខ្លះគេយកមកលក់បាន ១០ម៉ឺនបាត ១៥ម៉ឺនបាត ខ្លះដល់២០ម៉ឺនបាត ។

ធានី ៖ តែនៅខាងភូមិយើងមានទាក់ទងរឿងនឹងដែរ?

ធឿយ ៖ មាន នេះចាប់ប៉ុន្មានថ្ងៃមិនទាន់លែងផងចូលគុលាការ ។

ធានី ៖ រឿងអ្នកដែលមកគាស់ហ្នឹង?

ធឿយ ៖ បាទ!

ធានី ៖ យើងអត់មានចាត់វិធានការណ៍អីផ្សេងក្រៅពីរឿងហ្នឹង ដូចថាប្រាប់ពីរឿងបុណ្យបាប?

ធឿយ ៖ មានៗឯកសារ យើងមានប្រជុំប្រាប់ ហើយយើងមានប្រកាសតាមមេក្រូ តាមប៉ុស្តិ៍វិទ្យុអីយើងចេះតែផ្សាយ ។

ធានី ៖ តែនៅតែមានអ្នកធ្វើទៀត?

ធឿយ ៖ បាទ! មានអ្នកធ្វើនៅតែលួចធ្វើ ។

ធានី ៖ ហើយអ្នកដែលលួចធ្វើចឹង ដែលធ្លាប់មានឃើញរឿងអីកើតឡើងទេ?

ធឿយ ៖ ទេ!វាអាខ្លះទៅវាចេះតែលួចបានទៅវាសុខសាន្តទៅ រករឿង ។ ខ្ញុំជឿងថារបស់ដែលលួចគេវាមិនបានយូរទេ ។

ធានី ៖ ចឹងបានន័យថាពូអត់ដឹងថាកាលពីមុនមកហេតុអីបានបន្ទាយឆ្មារជាកន្លែងសពបូរាណផ្នូរបូរាណក៏អត់ដឹងដែរ?

ធឿយ ៖ បាទ! អត់ដឹងដែរ ។

ធានី ៖ គ្រាន់តែពេលមកនៅហ្នឹងគឺសម័យឥស្សរៈ សម័យបារាំងហើយ?

ធឿយ ៖ បាទ!

ធានី ៖ សម័យបារាំង គឺសុទ្ធតែព្រៃទេ ហើយមានប្រាសាទមួយ?

ធឿយ ៖ បាទ!

ធានី ៖ មានប្រាសាទមួយ សុទ្ធតែព្រៃខ្លា ព្រៃអីនៅទេ?

ធឿយ ៖ បាទ! សុទ្ធតែព្រៃទេ ។

ធានី ៖ ដល់ពេលក្រោយមកទៀតបានចាប់ផ្តើមកកើតទៅភូមិឃុំ ។ ចុះកាលពេលសម័យខ្មែរក្រហមអីកន្លែងហ្នឹងជាសមរភូមិក្តៅអីចឹង?

ធឿយ ៖ អឺ! សម័យខ្មែរក្រហមអានេះវា ។

ធានី ៖ ជាភូមិអ្នកស្រុក?

ធឿយ ៖ ជាភូមិអ្នកស្រុក ។

ធានី ៖ ដល់ពេលសម័យវៀតណាមចូលអីចឹង ជាសមរភូមិច្បាំងគ្នាអស់ផ្ទះអស់ស្រុក?

ធឿយ ៖ បាទៗ នេះហើយកន្លែងសមរភូមិក្តៅ មិនមែនសល់ត្រឹមផ្ទះ សល់តែបាតដី នេះឆេះអស់ ហើយដែលមករស់នៅផ្ទះនេះ សុទ្ធតែផ្ទះធ្វើថ្មីទាំងអស់ មករលីងឆេញអស់អត់មានអីទេ ឆេះអស់ ។

ធានី ៖ ចឹងពូមានអីចង់សួរខ្ញុំវិញទេ ដូចថាចង់សួរអីខ្ញុំវិញ ឬមានសំនូមពរអី?

ធឿយ ៖ វាចេះខ្ញុំគ្រាន់ថាមានសំណូមពរមួយ កាលដែលខ្ញុំបានចូលរួមបានសង្កេតការដែលយើងតុលាការខ្មែរក្រហម កាលដែលយើងកាត់ទោសនួន ជានឹង បាទ!ខ្ញុំក៏បានធ្លាប់ចូលនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាលេខប៉ុន្មានលេខ៦៦ ។

ធានី ៖ ពូចាំទៀត?

ធឿយ ៖ បាទ!

ធានី ៖ យ៉ាងម៉េចទៅពូ យ៉ាងម៉េច?

ធឿយ ៖ ហើយគាត់បានប្រាប់ថា យើងមិនបានអ្វីជូនបងប្អូនទេ យើងគ្រាន់តែ យើងមានដូចជាថាសម្រាប់កសាងដូចជាផ្តល់អ្វីមួយដល់ជីស្រះដីអីទៅ ដល់នេះវាអត់បានឃើញ ។

ធានី ៖ ចឹងអ្នកណាអ្នកនិយាយ?

ធឿយ ៖ បាទ! នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងឯង ព្រោះយើងបាននៅប្រជុំនោះពេលមួយថ្ងៃ ហើយនៅយើងនៅរៀនធ្វើពាក្យបណ្តឹង ។

ធានី ៖ នៅរៀនធ្វើពាក្យបណ្តឹង កាលនោះពូបានចូលរួមក្នុងការដាក់ពាក្យបណ្តឹងដែរអត់ មានលិខិតថ្លែងអំណរគុណដែរអត់?

ធឿយ ៖ បាទ! មានផ្ញើមកក្រោយ គាត់ផ្ញើមកក្រោយ ។

ធានី ៖ ចឹងពូមានអីចង់និយាយទៀតទេ?

ធឿយ ៖ ប៉ុន្តែនោះគ្រាន់តែ ចាំមើលបណ្តាំរបស់គាត់ វាអត់ឃើញចេះណា ។

ធានី ៖ អត់ឃើញថាមានជាអណ្តូងទឹកជាអី?

ធឿយ ៖ បាទ! ឬស្រះអីគាត់ឲ្យ ។

ធានី ៖ ចេះពូនូវអ្វីដែលពូបាននិយាយហ្នឹង គឺនៅក្នុងពាក្យបណ្ដឹងរបស់តុលាការដែលខាងតុលាការគាត់ សួរមកយើង ថាតើយើងមានចង់បានសំណងអ្វីពីតុលាការមកវិញ ចឹងពូ?

ធឿយ ៖ បាទៗ នោះហើយ ។

ធានី ៖ អាហ្នឹងយើងបំពេញក្នុងពាក្យបណ្ដឹងមែនទេពូ?

ធឿយ ៖ បាទ! នោះហើយ ។

ធានី ៖ ចាំ!រឿងហ្នឹងជារឿងខាងតុលាការដែលគាត់ត្រូវដោះស្រាយ តើអ្វីដែលយើងស្នើសុំទៅតុលាការថានឹងមានសំណងមកដល់ជនរងគ្រោះខ្មែរក្រហមនឹង ថាជាអីមកវិញទេពូណាស់ ។ ហើយមិនមែនខាងពួកខ្ញុំទេ ។

ធឿយ ៖ បាទៗ ។

ធានី ៖ ពួកខ្ញុំគ្រាន់តែពន្យល់ពូពីកន្លែងហ្នឹង កន្លែងដែលពូបំពេញហ្នឹងគឺមានសំណង តុលាការស្នើសួរយើង ប៉ុន្តែជាសំណងហ្នឹងមិនប្រាកដថាមានអត់ទេ ។

ធឿយ ៖ បាទ!

ធានី ៖ ព្រោះគ្រាន់តែគេចង់ឲ្យយើងគិតថា បើសិនជាមានតើពូនឹងចង់បានអី គ្រាន់តែគេគិតចង់សាកសួរយោបល់យើងពូណា៎ ។

ធឿយ ៖ បាទៗ ។

ធានី ៖ ចាំ! ហើយធាតុពិតនោះ គឺខាងតុលាការជាអ្នកសម្រេចទេ ថាតើជាចុងក្រោយនៃការកាត់ទោសរបស់មេដឹកនាំខ្មែរក្រហមទាំងអស់ហ្នឹង តើប្រជាជនខ្មែរទូទាំងប្រទេសហ្នឹង នឹងបានសំណងជាអ្វីមកវិញពូណា៎ ។

ធឿយ ៖ បាទ!

ធានី ៖ ចាំ! មិនមែនជាខាងពួកខ្ញុំ ហើយក៏ខាងតុលាការក៏អត់ដឹងថាជាសំណង មិនប្រាកដថាអណ្ដូងទឹក ជាផ្លូវ ជាស្ពាន ជាអីមិនមែនទេពូណា៎ ។

ធឿយ ៖ បាទៗ ។

ធានី ៖ ពួកខ្ញុំអត់ទាន់ប្រាកដទេ ខាងតុលាការក៏អត់ដឹង គ្រាន់គាត់ចង់ដឹងយោបល់ពូផ្ទាល់ ដែលពូជាអ្នកដូចថាជនរងគ្រោះសម័យខ្មែរក្រហមចឹង ។

ធឿយ ៖ បាទៗ ។

ធានី ៖ ចង់ដឹងថាតើពូបានអី ដល់ពេលអ្នកផ្សេងចង់បានអី ហើយតើពូចង់បានអី ដល់ពេលអ្នកផ្សេងចង់បានអី ហើយតើអ្នកណាមានចំនួនច្រើនជាងអីចឹង តើថ្លឹងថ្លែងគួរដាក់អី ដើម្បីឲ្យសមស្របនឹងទឹកចិត្ត ក៏ដូចជាការប្រជាជនដែលប្រជាជនស្លាប់នៅសម័យនឹងចឹងពូណា៎ ។

ធឿយ ៖ បាទៗ ។

ធានី ៖ តែវាមិន និយាយទៅអាយុជីវិតមនុស្សយើងមិនអាចប៉ាន់ស្មានបានទេពូណា៎ ។

ធឿយ ៖ បាទ!

ធានី ៖ គ្រាន់នេះមួយជាការចងចាំរបស់យើង ។ ចា៎! ចឹងអ៊ីដែលពូរំពឹងថានឹងបាននោះ វានឹងបាន ឬ មិនបានវាអត់ទាន់ដឹងទេឥឡូវពូណា៎ ។

ធឿយ ៖ បាទ!

ធានី ៖ ចា៎! ព្រោះខាងតុលាការ គាត់ជាអ្នកសម្រេចនៅពេលចុងក្រោយនៃការប្រកាស ដូចថាហ៎!ពូបានឃើញនួន ជា ដែលគេកាត់ទោសហ្នឹង ប្រកាសនៅចុងក្រោយដែលថាមេដឹកនាំទាំង៤នាក់ ដែលចុងក្រោយដែលគេកាត់ទោសហ្នឹង ថានឹងបានជាប់ទោសប៉ុន្មានឆ្នាំ ហើយនឹងចេញអ៊ីជាសំណង ។

ធឿយ ៖ បាទ!

ធានី ៖ ដូចឌុច សំណងរបស់គាត់ ពូបានមើលទេ ថាឌុចចុងក្រោយ?

ធឿយ ៖ អត់បានមើលទេ ។

ធានី ៖ អត់បានមើលការកាត់ទោសឌុចទេពូ?

ធឿយ ៖ បាទ!

ធានី ៖ ក្នុងឌុចហ្នឹងគេឲ្យគាត់ជាប់ទោស៣៥ឆ្នាំ ហើយក្នុង៣៥ឆ្នាំហ្នឹងគេបន្ធូបន្ថយទោសគាត់៥ ហើយគាត់ត្រូវជាប់៣០ឆ្នាំទេ ព្រោះឌុចគេឃុំគាត់អត់មានច្បាប់ទម្លាប់ពូ ។

ធឿយ ៖ បាទ!

ធានី ៖ ដូចយើងចាប់គេយកមកឃុំខ្លួន ប៉ុន្តែអត់មានកាត់ទោសគាត់ម៉េចៗ ។

ធឿយ ៖ បាទ!

ធានី ៖ ដល់ចឹងគេលើកលែងទោសឲ្យគាត់៥ឆ្នាំ ហើយសរុបទៅតាំងពីគាត់ជាប់ទោសរហូតមកដល់ឥឡូវ នៅសល់តែរយៈពេល១៩ឆ្នាំទៀតទេ ដែលគាត់នឹងត្រូវយកមកកាត់ទោស អឺ!ដែលគាត់នឹងត្រូវ ដូចថាជាប់ទោសពី១៩ឆ្នាំទៅថ្ងៃមុខទៅគាត់នឹងអាចរួចខ្លួន នឹងបើសិនជាគាត់នៅមានជីវិតណា៎ពូ?

ធឿយ ៖ បាទៗ ឡើងចាស់ហើយ ។

ធានី ៖ ប៉ុន្តែឥឡូវគាត់អាយុច្រើនហើយ បើបូកហ្នឹងអាហ្នឹងយើងមិនដឹងថាតើមនុស្សយើងម្នាក់ៗអាច មានជីវិតដល់ហ្នឹងចឹង ។ អាហ្នឹងចឹងការកាត់ទោសរបស់ខាងតុលាការ ។ ហើយចំពោះសំណង ដែលខាងខុច នឹងត្រូវសងគេហ្នឹង ដែលខាងតុលាការនឹងចេញឲ្យ គឺប្រជាជនអស់ហ្នឹងគឺបាន ត្រឹមតែចារឈ្មោះខ្លួនឯងនៅក្នុងសាលាក្រមរបស់ខុចហ្នឹង ថាគាត់ជាជនរងគ្រោះផ្ទះអីចឹង ហើយដូចប្រជាជនយើងផ្សេង ជនរងគ្រោះអត់ផ្ទាល់ដូចថានៅពីចំងាយ ។

ធឿយ ៖ បាទ!

ធានី ៖ បានត្រឹមតែសរសេរឈ្មោះអីផង អត់បានជាអណ្តូងទឹកអីផង អាហ្នឹងពូ អាហ្នឹងខាងខុចដែល គេកាត់ទោសគាត់ហើយៗ ។

ធឿយ ៖ បាទ!

ធានី ៖ ឥឡូវនេះនៅសល់៤នាក់ទៀត ដែលពូបានមើលសៀវភៅៗ(ករណី០០២)ក្រហមហ្នឹង ៤ នាក់នឹងដែលមានខុច(ប្រឡំ) នួន ជា អៀង សារី ខៀវ សំផន។ ដែលពូធ្លាប់បានទៅមើល នួន ជានៅតុលាការហ្នឹង ឬក៏គេកំពុងរៀបចំកាត់ទោសហើយពូណា ។

ធឿយ ៖ បាទៗ ។

ធានី ៖ ចាំ! ហើយអ្នកអស់ហ្នឹង ខ្ញុំក៏អត់ដឹងថាតើខាងតុលាការគាត់នឹងចេញជាសំណងអី ដើម្បីឲ្យ ប្រជាជនបានចងចាំថា អ្នកអស់ហ្នឹងត្រូវជាប់ទោស នឹងមានសំណងដល់ប្រជាជន ។

ធឿយ ៖ បាទ!

ធានី ៖ ចឹងពូ ។

ធឿយ ៖ បាទ! ដូចថាមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់បានសួរដែរ សួរពីរឿងពាក្យបណ្តឹង បើសិនថា យើងនៅពាក្យបណ្តឹងរដ្ឋវេណីនេះ លោកពូឯងអត់បានសម្រាកទេ ពូឯងមេដឹកនាំខ្មែរក្រហម ទាំងប៉ុន្មាន គឺឡើងទៅគ្រប់មេដឹកនាំ ។ ដល់ហើយគាត់សួរយោបល់ខ្ញុំថា យើងគួរសម្រេច យ៉ាងម៉េច ដូចថាជាពាក្យបណ្តឹងធម្មតា ឬដកថយវិញ ។ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំដកថយ ហើយ ព្រោះខ្ញុំអឺ!ជាអ្នកស្រែចំការផង វាខាតពេលច្រើនចេះណា ខ្ញុំ ។

ធានី ៖ ក៏ធ្វើជាអ្នកប្តឹងធម្មតា?

ធឿយ ៖ បាទ!

ធានី ៖ ចឹងពូមានអីចង់បន្ថែមទៀតទេ?

ធឿយ ៖ មិនមានអីផង ។

ធានី ៖ ចឹងអរគុណពូច្រើន ។

ធឿយ ៖ បាទៗ ។

«ចប់»